# ទុក្ខកើតព្រោះអញ

រៀបរៀងដោយ

ភិក្ខុ ចិន-ចេន ឥន្ទប្បញ្ញោ

វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

# ទុក្ខកើតព្រោះអញ

រៀបរៀងដោយ

ភិក្ខុ ខិន-ភេន ឥន្ទបញ្ញោ

បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

ដោយពុទ្ធបរិស័ទវត្តពោធិវង្ស

ប្រទេសបារាំង

ព.ស. ២៥៤៤ គ.ស.២០០០

# អារម្ភកថា

ទុក្ខកើតព្រោះអញ ជាធម្មទេសនា ដែលខ្ញុំបានសម្តែង នៅថ្ងៃអាទិត្យ ៨ តុលា ព.ស.២៥៣៩ គ.ស១៩៩៥ ជាថ្ងៃបុណ្យកំណើតរបស់ខ្ញុំ ។ ឥឡូវ ខ្ញុំកែសម្រួល រៀបរៀង ធម្មទេសនានោះ បោះពុម្ពចែកជាធម្មទាន ក្នុងឱកាសថ្ងៃបុណ្យកំណើតខ្ញុំ អាទិត្យ ៨ តុលា ២០០០ នេះ ។ ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងឲ្យជាពន្លឺដល់លោក អ្នកអានខ្លះជាមិនខាន ។ ខ្ញុំរីករាយនឹងទទួលនូវគំនិតល្អ ៗ ពីលោក អ្នកអានដើម្បីកែសម្រួលកូនសៀវភៅនេះ សំរាប់បោះពុម្ពចែកជាធម្មទានតទៅមុខទៀត ។

ខ្ញុំសូមប្រគេន ជូនបុណ្យកុសល ដល់សព្វសត្វទាំងអស់ ។ សូមសព្វសត្វទាំងឡាយទាំងពួង កុំមានអញ កុំមានមានះ និង កុំលោភលន់ហួសហេតុពេក ។ សូមបងប្អូនខ្មែរ ស្រឡាញ់រាប់អានគ្នា អាណិតអាសូរគ្នា ជួយសង្គ្រោះគ្នា សាមគ្គីគ្នា កសាងជាតិ សាសនា យើងឲ្យថ្កុំថ្កើងរុងរឿងឡើងវិញ ។

វត្តពោធិវង្ស ថ្ងៃ ៨ តុលា ២០០០

**ភិក្ខុ ខិន សេន ឥន្ទបញ្ញោ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

# ទុក្ខកើតព្រោះអញ

## ទុ ក្ខ គឺ អ្វី ?

ការធន់នៅដែលមិនបាន នៃសង្ខារធម៌ទាំងឡាយទាំងពួង គឺវាត្រូវតែប្រែប្រួលផ្លាស់ប្តូរសភាពទៅតាមហេតុបច្ច័យ ហៅថាទុក្ខ ។ ម្យ៉ាងទៀត សេចក្តីលំបាកក្នុងកាយ ឬ សេចក្តីលំបាកក្នុងចិត្ត ហៅថាទុក្ខ ។

## ទុក្ខមាន ៣ យ៉ាង

### ១- ទុក្ខក្នុងព្រះត្រៃលក្ខណ៍

ទុក្ខក្នុងព្រះត្រៃលក្ខណ៍ សំដៅយកការធន់នៅដែលមិនបាន នៃសង្ខារទាំងឡាយទាំងពួង ទោះជាឧបាទិន្នកសង្ខារ គឺសង្ខារមានចិត្ត ដូចជា ទេវតា មនុស្ស សត្វ ជាដើមក្តី ទោះជាអនុបាទិន្នកសង្ខារគឺសង្ខារមិនមានចិត្ត ដូចជា ផ្ទះ រទេះ រថយន្ត ជាដើមក្តី ឬជាដំបូក ភ្នំ បឹង ស្ទឹង ជាដើមក្តី ។ សង្ខារគឺអ្វីដែលប្រជុំគ្នាកើតឡើង វត្ថុរួមផ្សំគ្នាក្តី ធម៌រួមផ្សំគ្នាក្តី ហៅថា សង្ខារបានទាំងអស់ ។ សង្ខារគ្រប់ប្រភេទទាំងអស់ ទោះបីមានចិត្តអាស្រ័យនៅក្តី មិនមានចិត្ត អាស្រ័យនៅក្តី តែងតែប្រែប្រួល សភាពរបស់ខ្លួនម្តងបន្តិច ។ តាមហេតុបច្ច័យ គ្រប់ពេលវេលា

ជាជរាប ឥតមានសង្ខារណា ស្ទម្បីតែមួយ អាចស្ថិតស្ថេរ គង់ធន់នៅ ជដែលបានឡើយ ។ ការគង់ធន់នៅជដែលមិនបាន នៃសង្ខារធម៌ ទាំងឡាយទាំងពួងនេះហើយ (មិនចាំបាច់បេះឈើ បេះយំស្រែកទេ) លោកហៅថា ទុក្ខ គឺទុក្ខក្នុងព្រះត្រៃលក្ខណ៍ ។ ទុក្ខនេះ ស៊ីសេចក្ដីធំទូលំទូលាយជាងគេ គឺមានគ្រប់សង្ខារទាំងអស់ (សាមញ្ញលក្ខណៈ) ទាំងមានវិញ្ញាណ (ចិត្ត) ទាំងឥតវិញ្ញាណ ។

## ២- ទុក្ខក្នុងអរិយសច្ច

ទុក្ខក្នុងអរិយសច្ច សំដៅយកទុក្ខ ១២ កង គឺ ១-ជាតិទុក្ខ ការកើត ជាទុក្ខ ២-ជរាទុក្ខ ការចាស់គ្រាំគ្រាជាទុក្ខ ៣-មរណទុក្ខ សេចក្ដីស្លាប់ ជាទុក្ខ ៤-សោកទុក្ខ សេចក្ដីក្រៀមក្រំជាទុក្ខ ៥-បរិទេវទុក្ខ សេចក្ដីខ្សឹកខ្សួល ជាទុក្ខ ៦-ទុក្ខទុក្ខ សេចក្ដីលំបាកកាយជាទុក្ខ ៧-ទោមនស្សទុក្ខ ការអាក់អន់ចិត្ត ជាទុក្ខ ៨-ឧបាយាសទុក្ខ ការតានតឹងចិត្ត ជាទុក្ខ ៩-អប្បិយេហិ សម្បយោគទុក្ខ ការជួបប្រសព្វដោយសត្វ និងសង្ខារ មិនជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ ១០-បិយេហិ វិប្បយោគទុក្ខ ការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ទាំងឡាយ ជាទុក្ខ ១១-យម្បិច្ឆំ ន លភតិ តម្បិទុក្ខ ប្រាថ្នារបស់ណាមិនបាន នោះក៏ជាទុក្ខ ១២-សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខ ពោលដោយបំប្រួញ ឧបាទានក្ខន្ធទាំងប្រាំ ជាទុក្ខ ។ ទុក្ខក្នុងអរិយសច្ចនេះ សំដៅយកទុក្ខរបស់ឧបាទិន្នកសង្ខារ គឺសង្ខារដែលមានចិត្ត មានវិញ្ញាណតែប៉ុណ្ណោះ មិនទូទៅដល់អនុបាទិន្នក-

សង្ខារផងទេ  ប៉ុន្តែ វាមានសេចក្តីទូលាយដល់ទុក្ខកាយ ទុក្ខចិត្ត ទុក្ខរូប ទុក្ខនាម ផងដែរ ។ ទុក្ខនេះ ស៊ីសេចក្តីបានខ្នាតកណ្តាល ។

**៣- ទុក្ខវេទនា**

ទុក្ខវេទនា  សំដៅយកចិត្តសោយអារម្មណ៍មិនសប្បាយក្នុងពេលដែលអាយតនៈខាងក្នុងគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ប៉ះនឹងអាយតនៈខាងក្រៅគឺរូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មៈ ហើយកើតវិញ្ញាណ ។ កាលបើធម៌ ៣ គឺ អាយតនៈខាងក្នុងអាយតនៈខាងក្រៅ និងវិញ្ញាណ រួមគ្នាកើតបានជាផស្សៈ ទើបជាបច្ច័យឲ្យកើតវេទនា គឺ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ។ ទុក្ខវេទនា សំដៅយកតែទុក្ខវេទនាមួយប៉ុណ្ណោះ មិនទូទៅដល់សុខវេទនា ឬ អទុក្ខមសុខវេទនា ផងទេ ។ ទុក្ខវេទនានេះ ស៊ីសេចក្តីបានតូចជាងគេទាំងអស់ ។

**រូបភាពនៃទុក្ខ**



ទុក្ខទាំង ៣ យ៉ាងនេះ វាជាប់ប្រទាក់ប្រទងគ្នា ពិបាកនឹងវែកញែកឲ្យដាច់ពីគ្នាណាស់ យើងត្រូវតែសិក្សាឲ្យបានដឹងច្បាស់។ ប៉ុន្តែបើគេសួរថា ទុក្ខកើតព្រោះអញ សំដៅយកទុក្ខណា ? យើងត្រូវឆ្លើយថា សំដៅយកទុក្ខក្នុងអរិយសច្ច ព្រោះជាទុក្ខរបស់សង្ខារ ដែលមានចិត្តមានវិញ្ញាណ មានសេចក្តីសំគាល់ថា អញ ថារបស់អញ ។

## អញគឺអ្វី?

តាមវចនានុក្រមខ្មែរ មានសេចក្តីពន្យល់ដូចតទៅនេះ : អញ(អាញ់) បុ.ស. ខ្ញុំ (ជាអញ្ញត្រសព្ទ ) ។ ពាក្យសំរាប់ហៅខ្លួនឯងជាសម្តីក្មេង និយាយទៅរកក្មេងផងគ្នា ឬមនុស្សចាស់និយាយទៅរកក្មេង និយាយទៅរកមនុស្សស្មើភាពដែលស្និទ្ធស្នាល ឬក៏អ្នកធំនិយាយទៅរកអ្នកតូចដោយស្និទ្ធស្នាល ឯងទៅចុះ អញមិនទៅទេ ! --។

អញគឺអ្វី? ហេតុអ្វីក៏មិនសរសេរ អាញ់ ហើយបែរទៅជាសរសេរ អញ ដូចនេះទៅវិញ ពិបាករកហេតុផលណាស់ ។ សម្តេចព្រះសង្ឃរាជ ជួន-ណាត ព្រះបិតាវចនានុក្រមខ្មែរ ព្រះអង្គមិនបានអធិប្បាយទុកទេ ។ ខ្ញុំសន្និដ្ឋានថា អញ ប្រហែលជាក្លាយមកពីភាសាបាលី អញ្ញ ប្រែថាដទៃ ... ។ មនុស្សខ្លះយល់ឃើញថា មនុស្សយើងមិនមែនមានត្រឹមតែរូបកាយប៉ុណ្ណឹងទេ មានស្អីដទៃទៀតអាស្រ័យនៅក្នុងរូបកាយនេះផងដែរ ។ ស្អីដទៃដែលអាស្រយ័នៅក្នុងរូបកាយនោះ គេហៅថាអាត្ម័ន អត្តាអញឬព្រលឹង។ អ្នកខ្លះយល់ឃើញវែងឆ្ងាយហួសពីណឹងទៅទៀតថា អាត្ម័ន អត្តា អញ ឬ

ព្រលឹងណឹង ព្រះជាម្ចាស់ស្ថានលើលោកប្រទានឲ្យមក វាជាសភាវៈទៀងទាត់ស្ថិតស្ថេរ មិនចេះស្លាប់រលត់រលាយបាត់បង់ទៅណាទេ បើរូបកាយបែកធ្លាយស្លាប់ទៅ អត្តា ឬ អញ វាចូលទៅអាស្រ័យនៅនឹងរូបកាយថ្មីទៀត ចេះតែផ្លាស់ប្តូររឿយ ៗ ទៅ ពេលណាវាស្អាតម៉ត់ចត់ អស់កិលេសហើយ វានឹងចូលទៅអាស្រ័យ នៅរួមជាមួយនឹង បរមាត្ម័នឬព្រះព្រហ្មវិញ ។ គំនិតនេះហើយដែលនាំឲ្យកើតទិដ្ឋិ (មិច្ឆាទិដ្ឋិ) មានះតណ្ហា ឬ និយាយថា តណ្ហា មានះ ទិដ្ឋិដូចនេះក៏មាន ។

ព្រះពុទ្ធសម្តែងថា នៅក្នុងមនុស្សទាំងមូលមិនមាន អាត្ម័ន អត្តា អញ ព្រលឹង ឬអ្វីៗទេ មានតែខន្ធប្រាំ (រូប+នាម) តែប៉ុណ្ណោះ ។ មនុស្ស ជាសង្ខារធម៌ ជាខន្ធបញ្ចកៈ រួមប្រជុំនៃខន្ធប្រាំគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ រូប គឺធាតុមិនដឹង បានដល់ ដី ទឹក ភ្លើង ខ្យល់ខាងក្នុង វេទនា ធាតុដឹងសោយអារម្មណ៍ សុខ ទុក្ខ មិនទុក្ខមិនសុខ សញ្ញា ធាតុដឹងកត់ចំណាំ រូប សម្លេង ។ល។ តូច ធំ ខ្មៅ ស វែង ខ្លី ជាដើម សង្ខារ ធាតុដឹងគិតគូរធ្វើល្អអាក្រក់ វិញ្ញាណ ធាតុដឹងគឺឃើញ ឮ ជាដើម(១) ។ ខន្ធប្រាំបំប្រួញឲ្យខ្លីមាន ២ គឺ រូប និង នាម ។ រូប ចាត់ជា រូប , វេទនា សញ្ញា សង្ខារ វិញ្ញាណ ចាត់ជានាម ។ រូប

-----------------

(១) ក្នុងពុទ្ធសាសនា ធាតុមានច្រើនណាស់ នានាធាតុ អនេកធាតុ សូម្បីជានាមធម៌ក៏វាប់ថាធាតុ កិលេសក៏រាប់ថាធាតុ និព្វាន ក៏រាប់ថាធាតុដែរ ។

កើតរលត់ដោយហេតុបច្ច័យ មានក្តៅ ត្រជាក់ជាដើម នាម កើតរលត់ដោយហេតុបច្ច័យដែរ តែមិនពឹងផ្អែកទៅលើក្តៅត្រជាក់ជាដើមដូចរូបទេ។ រូបនាម ឬ ខន្ធប្រាំ មិនមាននរណាជាអ្នកបង្កើតទេ មិនមាននរណាជាម្ចាស់លើវាទេ វាកើតដោយអាស្រ័យហេតុបច្ច័យរបស់វា វាប្រែ ប្រួល និងរលត់ទៅតាមហេតុបច្ច័យរបស់វាទាំងអស់ វាអត់ខ្វាច អត់ស្តាប់បង្គាប់បុគ្គលណាទេ វាប្រព្រឹត្តទៅតាមហេតុបច្ច័យ តែប៉ុណ្ណោះ ។ អញ តាមសេចក្តីពិត វាគ្មានទេ ប៉ុន្តែ បើនិយាយ ជាបុគ្គលាធិដ្ឋាន អញ គឺខន្ធប្រាំ បើនិយាយជា ធម្មាធិដ្ឋាន អញ គឺ កិលេស វាគ្មានស្អីទៀតឯណានោះទេ ។ ប៉ុន្តែ មនុស្សល្ងង់ប្រកាន់ជឿស្មាន ។ ថា ក្នុងរូបមានអត្តា មានអញ ឬ ក្នុង វេទនា សញ្ញា សង្ខារ វិញ្ញាណ មានអត្តា មានអញ ឬ យ៉ាងហោចណាស់ក៏ត្រូវមាន អត្តា នៅក្នុងខន្ធណាមួយដែរ ។ ជំនឿបែបនេះ ជាជំនឿ មិនត្រឹមត្រូវ ចាត់ជា សក្កាយទិដ្ឋិ ។

## សក្កាយទិដ្ឋិ ២០

១- រូបំ អត្តតោ សមនុបស្សតិ យល់ឃើញរូបថាជាខ្លួន (អត្តា) ។

២- រូបវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានរូប ។

៣- អត្តនិ រូបំ សមនុបស្សតិ យល់ឃើញរូបក្នុងខ្លួន ។

៤- រូបស្មឹ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងរូប ។

៥- វេទនំ អត្តតោ សមនុបស្សតិ យល់ឃើញវេទនាថាជាខ្លួន ។

៦- វេទនាវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានវេទនា ។

៧- អត្តនិ វេទនំ សមនុបស្សតិ យល់ឃើញវេទនាក្នុងខ្លួន ។
៨- វេទនាយ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងវេទនា ។
៩- សញ្ញំ អត្តតោ សមនុបស្សតិ យល់ឃើញសញ្ញាថាជាខ្លួន ។
១០- សញ្ញាវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានសញ្ញា ។
១១- អត្តនិ សញ្ញំ សមនុបស្សតិ យល់ឃើញសញ្ញាក្នុងខ្លួន ។
១២- សញ្ញាយ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងសញ្ញា ។
១៣- សង្ខារេ អត្តតោ សមនុបស្សតិ យល់ឃើញសង្ខារថាជាខ្លួន ។
១៤- សង្ខារវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមានសង្ខារ ។
១៥- អត្តនិ សង្ខារេ សមនុបស្សតិ យល់ឃើញសង្ខារក្នុងខ្លួន ។
១៦- សង្ខារេសុ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងសង្ខារ
១៧- វិញ្ញាណំ អត្តតោ សមនុបស្សតិ យល់ឃើញវិញ្ញាណថាជាខ្លួន ។
១៨- វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនថាមាន វិញ្ញាណ ។
១៩- អត្តនិ វិញ្ញាណំ សមនុបស្សតិ យល់ឃើញវិញ្ញាណក្នុងខ្លួន ។
២០- វិញ្ញាណស្មឹ អត្តានំ សមនុបស្សតិ យល់ឃើញខ្លួនក្នុងវិញ្ញាណ(២) ។

កាលបើមានទិដ្ឋិដូចនេះហើយ មានះសេចក្ដីប្រកាន់ខ្លួន អតិមានះ

------------------------

(២)សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ ចូឡវេទល្លសូត្រ ២២ / ១៤៧ /២៩១
សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ទិដ្ឋិកថា ៧០/ ២០/ ២២

ការមើលងាយគេ នឹងកើតឡើងបន្តទៅទៀត ។ មានះ នេះ ខ្មែរយើងនិយមប្រើជា មានះ ។

## មានះ សេចក្តីប្រកាន់ខ្លួន ៩ យ៉ាង

១- សេយ្យស្ស សេយ្យោហមស្មីតិ មានោ បុគ្គលអ្នកប្រសើរ
មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរជាងគេ ។

២- សេយ្យស្ស សទិសោហមស្មីតិ មានោ បុគ្គលអ្នកប្រសើរ
មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើនឹងគេ ។

៣- សេយ្យស្ស ហីនោហមស្មីតិ មានោ បុគ្គលអ្នកប្រសើរ
មានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាបជាងគេ ។

៤- សទិសស្ស សេយ្យោហមស្មីតិ មានោ បុគ្គលអ្នកស្មើ
មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរជាងគេ ។

៥- សទិសស្ស សទិសោហមស្មីតិ មានោ បុគ្គលអ្នកស្មើ
មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើនឹងគេ ។

៦- សទិសស្ស ហីនោហមស្មីតិ មានោ បុគ្គលអ្នកស្មើ
មានសេចក្តីប្រកាន់ថា អញជាបុគ្គលថោកទាបជាងគេ ។

៧- ហីនស្ស សេយ្យោហមស្មីតិ មានោ បុគ្គលអ្នកថោកទាប
មានសេចក្តីប្រកាន់ថា អញជាបុគ្គលប្រសើរជាងគេ ។

៨- ហីនស្ស សទិសោហមស្មីតិ មានោ បុគ្គលអ្នកថោកទាប
មានសេចក្តីប្រកាន់ថា អញជាបុគ្គលស្មើនឹងគេ ។

៩- ហីនស្ស ហីនោហមស្មីតិ មានោ បុគ្គលអ្នកថោកទាប

មានសេចក្ដីប្រកាន់ថា អញជាបុគ្គលថោកទាបជាងគេ (៣) ។

មានះនេះ បើប្រកាន់ថាខ្លួនប្រសើរជាងគេ រមែងមើលងាយគេ មិនចង់ទាក់ទងជាមួយគេទេ ព្រោះគេ ថោកទាបជាងខ្លួន។ បើប្រកាន់ថា ស្មើ ៗ គ្នា មិនបាច់ទាក់ទងគេទេ នាំឲ្យតែខាតពេលវេលា ព្រោះវាស្មើៗតែគ្នា ។ បើប្រកាន់ថាថោកទាបជាងគេ មិនបាច់ទាក់ទងជាមួយគេទេ យើងថោកទាប ថោកទាបតែយើងទៅ កុំទៅរវល់នឹងគេ ។ មានះសុទ្ធតែជាកិលេសនាំឲ្យបាក់បែក នាំឲ្យកើតទុក្ខទាំងអស់ ។

បើមានទិដ្ឋិសេចក្ដីយល់ឃើញដូចនេះ បើមានមានះ សេចក្ដីប្រកាន់ខ្លួនដូចនេះ សេចក្ដីសំគាល់ថារបស់អញ និងសេចក្ដីចង់បាន ដើម្បីអញ ក៏កើតឡើងរឿយ ៗ នេះគឺតណ្ហា ។

## តណ្ហា ៣ យ៉ាង

១- កាមតណ្ហា ចំណង់ក្នុងកាម ចង់សប្បាយនឹង រូប សម្លេង

ក្លិន រស ផោដ្ឋព្វៈ ។

២- ភវតណ្ហា ចំណង់ក្នុងភព ចង់កើត ចង់បាន បើបានហើយ

ចង់ឲ្យនៅស្ថិតស្ថេរ ។

៣- វិភវតណ្ហា ចំណង់ក្នុងវិភព ចង់មិនបាន ចង់មិនជួប

---

(៣) សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស ទុដ្ឋដ្ឋកសូត្រ ៦៤ /១០២/១៤៩

ចង់ឲ្យផុតពីអ្វីដែលបានដែលជួបហើយ (៤) ។

## តណ្ហា ៦ យ៉ាង

១- រូបតណ្ហា ចំណង់ក្នុងរូប

២- សទ្ទតណ្ហា ចំណង់ក្នុងសម្លេង

៣- គន្ធតណ្ហា ចំណង់ក្នុងក្លិន

៤- រសតណ្ហា ចំណង់ក្នុងរស

៥- ផោដ្ឋព្វតណ្ហា ចំណង់ក្នុងផោដ្ឋព្វៈ

៦- ធម្មតណ្ហា ចំណង់ក្នុងធម្មៈ(៥) ។

## តណ្ហា ១០៨ យ៉ាង

តណ្ហាវិចរិតខាងក្នុង ១៨ បូកនឹងតណ្ហាវិចរិតខាងក្រៅ ១៨ ត្រូវជា ៣៦ ជាអតីតៈ ៣៦ ជាបច្ចុប្បន្ន ៣៦ ជាអនាគត ៣៦ បូករួម ត្រូវជា តណ្ហា ១០៨ យ៉ាង (៦) ។

ម្យ៉ាងទៀត អាយតនៈខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មនៈ (ចិត្ត) គុណនឹង តណ្ហា ៣ គឺ កាមតណ្ហា -

---

(៤) វិនយបិដក មហាវគ្គ ៦/១៤/៣១ សុត្តន្តបិដក ទីឃនិកាយ ១៧/១៣៤/២៨៧ សុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាត ៤៦/ ១០៦/ ៣២៥

(៥) សុត្តន្តបិដក ទីឃនិកាយ មហាសតិប្បដ្ឋានសូត្រ ១៧/ ១៣៥/ ២៩០ សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ ៣១/ ១០/ ៦

(៦) សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣/ ៤៩/ ១៧៩

ភវតណ្ហា វិភវតណ្ហា ត្រូវជា ១៨ ។ អាយតនៈខាងក្រៅ ៦ គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មៈ គុណនឹងតណ្ហា ៣ គឺ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ត្រូវជា ១៨ ។ ១៨+១៨=៣៦ តណ្ហា ។ ជាអតីតៈ ៣៦ ជាបច្ចុប្បន្ន ៣៦ ជាអនាគត ៣៦ បូករួមត្រូវជា តណ្ហា ១០៨ យ៉ាង ។ នេះ មតិរបស់លោកអ្នកប្រាជ្ញជំនាន់ក្រោយ ។

## អវិជ្ជា និង តណ្ហា

ធម៌ទាំង ២ នេះ កើតឡើងអាស្រ័យគ្នានឹងគ្នា លោកចាត់ជាមូល គឺជាឫសគល់នៃសំសារវដ្ត ។ តណ្ហា កើតមកពីអវិជ្ជា អវិជ្ជា កើតមកពីតណ្ហា គឺព្រោះតែមានអវិជ្ជា សេចក្តីមិនដឹងច្បាស់ ងងឹតងងល់ ជាឫសគល់ បានជានាំឲ្យកើតតណ្ហា ចំណង់ខ្លាំងក្លាឡើងហើយក៏ព្រោះតែ មានតណ្ហាចំណង់ខ្លាំង បានជាបិទបាំងជិតងងឹត មិនដឹងច្បាស់ គឺអវិជ្ជា កើតឡើង ។ អវិជ្ជា ជាអតីតមូល តណ្ហា ជាបច្ចុប្បន្នមូល បើរំលាយ មូលទាំង ២ នេះបាន សំសារវដ្ត ឈប់វិល រឿងត្រូវចប់ចូលនិព្វាន ។

## អវិជ្ជា សេចក្តីមិនដឹងច្បាស់

ភិក្ខុ ១ រូប ទូលសួរព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន អវិជ្ជា អវិជ្ជា នោះតើដូចម្តេច? បុគ្គលប្រកបដោយអវិជ្ជា តើដោយហេតុ យ៉ាងណា?

ព្រះពុទ្ធត្រាស់ថា អវិជ្ជា គឺសេចក្តីមិនដឹងច្បាស់ បុគ្គលប្រកបដោយ អវិជ្ជា គឺអ្នកមិនដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ

មិនដឹងច្បាស់នូវហេតុនាំឲ្យកើត រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនដឹងច្បាស់នូវសេចក្តីរលត់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ សេចក្តីរលត់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ។ ម្នាលភិក្ខុ នេះ ហៅថា អវិជ្ជា បុគ្គលប្រកប ដោយអវិជ្ជា ដោយហេតុយ៉ាងនេះ (៧) ។

## អញ នាំឱ្យកើតទុក្ខដូចម្តេច ?

១-បុគ្គលខ្លះ យល់ឃើញថា ខន្ធប្រាំគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអត្តា ជាអញ ឬយល់ឃើញថា ក្នុងខន្ធប្រាំ មានអត្តា មានអញ ។ យើងគប្បីសង្កេតពិនិត្យ ពិចារណាមើលឲ្យច្បាស់ តើសេចក្តីពិតរបស់ខន្ធប្រាំវាយ៉ាងម៉េច តើបុគ្គលអ្នកប្រកាន់ជឿថា មានអត្តា មានអញ មានបានប្រយោជន៍អី ឬខូចប្រយោជន៍អីដែរ ព្រោះយល់ឃើញដូចនោះ។

ក្នុងអនត្តលក្ខណសូត្រ ព្រះពុទ្ធសម្តែងថា រូបំ ភិក្ខវេ អនត្តា ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា (គ្មានអត្តា គ្មានអញទេ) ។ បើរូបជា អត្តា ជាអញ រូបមិនគប្បីមានចាស់ ឈឺ ស្លាប់ទេ បុគ្គលគប្បី មានអំណាចបង្គាប់បញ្ជារូប ឲ្យទៅជាយ៉ាងនេះយ៉ាងនោះ បានតាមបំណងរបស់ខ្លួន ប៉ុន្តែ ព្រោះរូបជាអត្តា គ្មានអញ បានជារូប ចេះតែប្រែ

---

( ៧ ) សុត្តន្តបិដក សំយុត្តនិកាយ ធម្មកថិកវគ្គ ៣៤-២៧-១៣

ប្រួលចាស់ ឈឺ ស្លាប់ តាមច្បាប់របស់វាជាធរាបរៀយៗ ទៅជាធម្មតា ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏ជាអនត្តា គ្មានអត្តា គ្មានអញ តែងតែប្រព្រឹត្តទៅ តាមន័យដូចគ្នានឹងរូបនោះដែរ(៨) ។

សេចក្តីពិត រឿងខន្ធប្រាំនេះ វាគ្មានអត្តា គ្មានអញ ដូចជា ព្រះពុទ្ធទ្រង់សម្តែងទុកដូចនោះមែន ។ វាតែងប្រែប្រួល ចាស់ ឈឺ ស្លាប់ ជាធម្មតា គ្មានបុគ្គលណាជាម្ចាស់លើវាបានទេ ។ កាលបើវា ប្រព្រឹត្តទៅខុសបំណងរបស់មនុស្សយ៉ាងនេះ បុគ្គលអ្នកប្រកាន់ជឿថា ខន្ធប្រាំមានអត្តា មានអញ តែងតែកើតទុក្ខសោកស្តាយកន្ទក់កន្ទេញ ព្រោះតែជំនឿខុសរបស់ខ្លួននោះ។ នេះហៅថា ទុក្ខកើតព្រោះអញ ។

២- បុគ្គលអ្នកមានទិដ្ឋិយល់ឃើញថា មានអត្តា មានអញ តែងតែមាន មានះ សេចក្តីប្រកាន់ខ្លួនមានប្រការផ្សេងៗ ។ អ្នកខ្លះប្រកាន់ជាតិ អ្នកខ្លះប្រកាន់គោត្រ ពូជពង្សវង្សត្រកូល អ្នកខ្លះប្រកាន់យសសក្តិ អ្នកខ្លះប្រកាន់ចំណេះវិជ្ជា អ្នកខ្លះប្រកាន់ទ្រព្យសម្បត្តិ ជាដើម ហើយប្រមាថមើលងាយអ្នកដទៃ ។ ឧទាហរណ៍ អញ ពូជឯកឧត្តម ... អ្អែង ពូជអ្នកស្រែ អាសម្រែ ...។ គេមិនប្រកាន់តែមនុស្ស ប្រកាន់រហូតដល់ខ្មោច បើកូនអ្នកស្រែមានយសសក្តិ គេយកធ្វើប្តីបាន ប៉ុន្តែ បើឪពុកក្មេកគេស្លាប់ គេមិនឲ្យ យកអដ្ឋិធាតុ មកដាក់ក្នុងចេតិយរួមជាមួយនឹង

--------------------

(៨) វិនយបិដក មហាវគ្គ ៦/ ២០/ ៤០

អដ្ឋិធាតុឪពុកបង្កើតរបស់គេទេ គេថា ឯងពូជទាប ... នេះជារឿងដែលមានពិត ។ អញជានាម៉ឺនជាន់ចាស់ ឯងជាន់ក្រោយ... អញមានសញ្ញាប័ត្រធំ ឯងអត់សញ្ញាប័ត្រ ... មិនប្រកាន់តែ ពួកគ្រហស្ថ ព្រះសង្ឃអង្គខ្លះ ក៏ប្រកាន់សម្បើមណាស់ដែរ គួរឲ្យឆ្ងើម ...។

ក្នុងបរាភវសូត្រ ព្រះពុទ្ធសម្តែងថា

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

អ្នកដែលអាងជាតិអាងទ្រព្យស្តុកស្តម្ភ អាងគោត្រឧត្តមខ្លាំងហួសប្រមាណ ប្រមាថមើលងាយពួកញាតិសន្តាន នោះជាប្រធាននៃក្តីវិនាស (៩) ។

ក្នុងគម្ពីរ ធម្មបទដ្ឋកថា មានរឿងមួយ គួរឲ្យពិចារណា ព្រះចៅបសេនទិកោសល នៃក្រុងសាវត្ថី ដោយមានបំណង ឲ្យមានសេចក្តីស្និទ្ធស្នាលជាមួយនឹងព្រះពុទ្ធ បានបញ្ជូនទូតទៅទាក់ទង ស្នើសុំសក្យធីតា នៃក្រុងកបិលពស្តុ ១ ព្រះអង្គ មកអភិសេកជា អគ្គមហេសី ។

ស្តេចសក្យបានប្រជុំពិភាក្សាគ្នាថា ស្តេចបសេនទិកោសល មានឋានៈមិនស្មើនឹងស្តេចសក្យទេ បើយើងថ្វាយ សក្យធីតា ថ្លៃថ្លាទៅ វាមិនសមសក្តិគ្នាទេ ដូចនេះ ទើបសម្រេចថ្វាយធីតានៃសក្យមហានាម ឈ្មោះ វាសភខត្តិយា ជាកូនកើតជាមួយទាសី ។

--------------------

(៩) សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត ៥៤/ ១១/ ៣៨

ព្រះចៅ បសេនទិកោសល សប្បាយព្រះទ័យ ដោយមិន បាន ជ្រាបសេចក្តីពិតនេះ ក៏រៀបអភិសេក វាសភខត្តិយា ជាអគ្គមហេសី ធំ-លើសអស់ស្រីទាំង ៥០០ នាក់ ។ ពេលក្រោយមក មិនយូរប៉ុន្មាន ព្រះនាងវាសភខត្តិយា បានប្រសូតព្រះរាជបុត្រាមួយព្រះអង្គ ថ្វាយព្រះ-នាមថា វិឌូឌភៈ ។ លុះមានព្រះជន្មបាន៧ ព្រះវស្សា ព្រះរាជកុមារ វិឌូឌភៈ ទូលសួរព្រះមាតាថា ព្រះមាតាមិនមានព្រះអយ្យកោ ព្រះអយ្យិកា ព្រះញាតិវង្សាទេឬអ្វី បានជាមិនឃើញមាន នរណាផ្ញើបណ្ណាការជារបស់លេងមកឲ្យទូលបង្គំដូចជាព្រះរាជកុមារ ឯទៀត ៗ សោះ ។ ព្រះមាតាឆ្លើយប្រាប់ថា ព្រះអយ្យកោ ព្រះអយ្យិកា និងព្រះញាតិវង្សាមានច្រើនណាស់ ប៉ុន្តែ លោកនៅឆ្ងាយពេក បានជាមិនផ្ញើអ្វីមកថ្វាយ ។ លុះព្រះជន្មបាន ១៦ ព្រះវស្សា ព្រះអង្គម្ចាស់ វិឌូឌភៈ បានទូលស្នើសុំព្រះ-មាតា ដើម្បីស្តេចទៅក្រសាល ត្រកូល ព្រះរាជវង្សា ខាងព្រះមាតា ។ ព្រះមាតា ក៏ចេះតែឆ្លើយបណ្តោះបណ្តែដោយប្រការផ្សេងៗ ។ តមក ដោយយល់ឃើញថា មិនអាច នឹងទប់ទល់ តទៅទៀតបាន ទើបព្រះមាតាយល់ព្រមអនុញ្ញាត តាមសេចក្តីស្នើសុំ ហើយក៏ចាត់ចែងផ្ញើលិខិតថ្វាយព្រះអយ្យកោ អយ្យិកា ដើម្បីទ្រង់ជ្រាបពត៌មានជាមុន ។

ពួកស្តេចសក្យ កាលបើបានឮដំណឹងដូចនោះ បានពិគ្រោះគ្នាថា ដើម្បីកុំឲ្យសៅហ្មងទាក់ទងនឹងការគោរព វិឌូឌភៈ ស្តេចសក្យក្មេងៗ ត្រូវតែឲ្យចេញទៅកាន់ជនបទផ្សេង ៗ ទាំងអស់ ។ វិឌូឌភៈ

យាងទៅដល់ក្រុងកបិលពស្តុ បានជួបសុទ្ធតែស្តេចសក្យចាស់ៗ និងរៀមច្បងទាំងឡាយ ក៏ក្រាបថ្វាយបង្គំ ព្រះអយ្យកោ ព្រះអយ្យិកា ព្រះបិតុលា ព្រះមាតុលា ។ល។ គ្រប់ព្រះអង្គរឿយៗទៅ មិនឃើញ មានស្តេចសក្យសូម្បីតែ ១ អង្គ ធ្វើសេចក្តីគោរពក្រាបថ្វាយបង្គំ ដល់ខ្លួនវិញគ្មានឡើយ ទើបដណ្តឹងសួរថា នៅទីនេះ មិនមានស្តេច សក្យក្មេងៗទេឬ? គេឆ្លើយប្រាប់ថា ស្តេចសក្យក្មេងៗមានដែរ ប៉ុន្តែ មានភារកិច្ចត្រូវចេញទៅកាន់ជនបទអស់ហើយ ។ ព្រះអង្គម្ចាស់ វិឌូឌភៈ គង់ស្នាក់ក្រសាល ២,៣ ថ្ងៃ គួរដល់ព្រះអធ្យាស្រ័យហើយ ក៏ក្រាបបង្គំលាត្រឡប់ទៅសាវត្ថីវិញ ។

ធ្វើដំណើរចេញទៅបានបន្តិច អាមាត្យម្នាក់ភ្លេចអាវុធរបស់ខ្លួន ក៏វិលត្រឡប់មកយកអាវុធវិញ ពេលនោះ បានឃើញបានពួនាងទាសីទាំងឡាយ កំពុងតែយកទឹកលាយដោយទឹកដោះគោ លាងសំអាតទីកន្លែងដែលព្រះអង្គម្ចាស់ វិឌូឌភៈគង់ ព្រមទាំងជេរប្រមាថ ថាជាស្តេចពូជអម្បូរនាងទាសីអប្រិយចង្រៃ បានជានាំឲ្យលំបាកដល់ពួកយើងយ៉ាងនេះ ។ អាមាត្យក្រាបទូលសេចក្តីនោះ ដល់ព្រះអង្គម្ចាស់វិឌូឌភៈសព្វគ្រប់ប្រការ ។ ព្រះអង្គម្ចាស់ វិឌូឌភៈ ចងគំនុំ ក្នុងព្រះទ័យថា ថ្ងៃនេះគេយកទឹកលាយដោយទឹកដោះគោលាងប្រាសាទ ថ្ងៃក្រោយ បើអាត្មាអញ បានឡើងសោយរាជ្យ នឹងលាងប្រាសាទ ដោយឈាមនៃពួកសក្យវិញ ជាពុំខាន ។

បន្ទាប់ពីព្រះចៅបសេនទិកោសល សោយព្រះទិវង្គតទៅ ព្រះអង្គម្ចាស់ វិឌូឌភៈ ឡើងសោយរាជ្យស្នងព្រះបិតា ទ្រង់នឹកភ្នក ដល់គំនុំចាស់

បានចាត់ចែងលើកកងទព័ សំដៅទៅក្រុងកបិលពស្តុ ព្រះសាស្តាទ្រង់ជ្រាប នូវហេតុការណ៏នោះ បានស្តេចយាងទៅគង់ ក្រោមម្លប់ដើមឈើមួយដើម ដែលមានស្លឹករវេចៗ។ ព្រះចៅ វិឌូឌភៈ ចូលទៅគាល់ ព្រមទាំងទូលសួរ ថា បពិត្រព្រះអង្គដ៏ចំរើន ដូចម្តេច បានជាព្រះអង្គ មិនគង់ក្រោមម្លប់ ដើមឈើ ដែលមានស្លឹកច្រើន? ព្រះពុទ្ធ ត្រាស់តបថា មហាបពិត្រ ម្លប់ញាតិត្រជាក់ជាងម្លប់ឈើទៅទៀត ។ ព្រះចៅ វិឌូឌភៈ យល់អត្ថន័យ ទើបបញ្ជាឲ្យកងទ័ពត្រឡប់វិញ ។ លើកទ័ពទៅលើកទី ២ ក៏យ៉ាងនេះ ទៀត ។ លើកទ័ពទៅលើកទី៣ ក៏យ៉ាងនេះទៀត ។ ព្រះពុទ្ធ ទ្រង់រំពឹង ពិចារណាឃើញថា កម្មរបស់ស្តេចសក្យ មានទម្ងន់ធ្ងន់ណាស់ ព្រះអង្គមិន អាចជួយទប់ទល់បាន ព្រះអង្គក៏ឈប់ស្តេចយាងទៅគង់ ក្រោមម្លប់ឈើ នោះទៀតទៅ ។ ព្រះចៅ វិឌូឌភៈ លើកទ័ពទៅលើក ទី ៤ ចូលក្រុង កបិលពស្តុយ៉ាងស្រួល សម្លាប់ស្តេចសក្យ ជិតផុតពូជ ព្រោះស្តេចសក្យ កាន់សីល សូម្បីបាញ់ទៅគេ ក៏បាញ់បង្ហួស (១០) ។ ស្តេចសក្យនៅសល់ ខ្លះដោយសារ ១- គេយកស្មៅឬដើមបបុសមកអែប ពេលដែលគេសួរថា នេះសក្យឬ? ឆ្លើយថា នេះស្មៅ ឬ នេះដើមបបុស សក្យស្មៅ សក្យ-

---

(១០) កាន់សីល ម៉េចក៏មិនកាន់ធម៌ផង នៅមានមានះអឺខ្លាំងម្ល៉េះ ។ កាន់សីល ត្រូវកាន់ធម៌ផង ទើបមាន សីលធម៌ ។ កាន់សីលត្រូវមានបញ្ញា ម៉េចក៏មិនប្រើ បញ្ញាការពារខ្លួនផង ។ កាន់សីលរបៀប ស្តេចសក្យនេះ មិនគួរយកតម្រាប់ តាមទេ ព្រោះកាន់សីលជ្រុល ភ្លេចធម៌ ភ្លេចបញ្ញា បានជាស្លាប់ជិតផុតពូជ ។

បបុស ។ ២- សក្យពួកមហានាម ដែលត្រូវជាព្រះអយ្យកោនៃព្រះចៅវិឌូឌភៈ ។

## មានះ នៃក្សត្រ

សងគំនុំរួចហើយ ព្រះចៅវិឌូឌភៈ ឲ្យគេរៀបចំ ព្រះស្ងោយជប់លៀង បានយាងសក្យមហានាម ព្រះអយ្យកោ មកសោយព្រះស្ងោយរួមគ្នា ។ សក្យមហានាម គិតថា បើអញមិនព្រមសោយរួម គេសម្លាប់ ទើបគិតរកឧបាយដោះស្រាយទៅស្រង់ទឹកសិន គេចរត់បាត់ទៅ ។ ខត្តិយោ អហំ ឥតិ មានោ ខត្តិយមានោ មានះ មានះរបស់ក្សត្រថា អញ ជាក្សត្រ ។ ស្ដេចក្ដី រាស្ត្រក្ដី បើអត់ មានធម៌ហើយ មានះដូចតែគ្នាទេ ប៉ុន្តែ ស្ដេចធ្លាប់ធំ ធ្លាប់សន្សំមានះ មកយូរហើយ មានះរែបបក្រាស់ជាងបន្តិចដែរ ។

## ច្បាប់ព្រះរាជសម្ភារ

ចង់បុណ្យបានបាប ចចើងចង់លាភ វែងបាត់ធនទៅ
មានះបាត់មិត្រ ឥតអ្នកជាជៅ ក្រេវក្រោធឃោរឃៅ
រមែងបាត់អង្គ ។

បើមានមានះហើយ ញាតិមិត្រចេះតែអស់ចេះតែរេចរិលហើយ បើថែមក្រេវក្រោធឃោរឃៅទៀត បាត់អង្គតែម្ដង ។ បាត់អង្គ មិនមែនបាត់ត្រឹមតែអវយវៈដៃជើងទេ ជីវិតក៏បាត់ដែរ ព្រោះអង្គ ប្រែថា ជីវិតក៏បាន ។ ទាំងអស់នេះ លោកហៅថា ទុក្ខកើតព្រោះ អញ ។

៣- បុគ្គលអ្នកមានអញច្រើន មានអញក្រាស់ តណ្ហា របស់គេក៏មានច្រើន មានក្រាស់ដែរ ។ គេចង់សប្បាយនឹង រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ មិនចេះឆ្អែត មិនចេះស្កប់ស្កល់ ។ ចង់សប្បាយ បើគិតមិនឆ្ងាយ ស្មានថាសេចក្ដីសុខ បើគិតឲ្យល្អិត គ្រប់មុខ ក្នុងសប្បាយនោះមានទុក្ខច្រើនណាស់ ។ ចង់សប្បាយ មុននឹងសប្បាយបន្តិចនោះ តើមានទុក្ខអ្វីខ្លះ? ពេលយើងសប្បាយ តើគេឯទៀតសប្បាយឬទេ? ប្ដីប្រពន្ធ កូនចៅ គេសប្បាយ ដែរឬទេ? សង្គម សុខសប្បាយដែរឬទេ? ក្រោយពីសប្បាយទៅ តើមានទុក្ខ មានបញ្ហាអីខ្លះដែរ? យើងត្រូវគិតឲ្យជ្រៅគិតឲ្យវែងឆ្ងាយ គិតឲ្យម៉ត់ចត់ល្អ ។ តណ្ហា ដូចជាទឹកអំបិល ផឹកមិនចេះឆ្អែតទេ រឹតតែផឹក រឹតតែស្រេក ។

បុគ្គលមានអញច្រើន លោភក៏មានច្រើនដែរ អ្វីៗ ក៏អញដែរ ប្ដីរបស់អញ ប្រពន្ធរបស់អញ កូនរបស់អញ ទ្រព្យរបស់អញ ។ល។ គេគិតឃើញតែរឿងអញ មិនឃើញរឿងគេទេ គេគិតឃើញ តែរឿងបានមិនឃើញរឿងបង់ទេ បានហើយចង់បានទៀត ឆ្ងៀតហើយឆ្ងៀតឥតគិតក្រែងយល់ឃើញតែខ្លួនឯង មិនយល់គេឯទៀតផង ។ គេប្រាប់ថា កុំទៅផ្លូវហ្នឹងអន្តរាយណាស់... ទៅ ទៅត្រូវគ្រាប់មីន ស្លាប់ ។ គេប្រាប់ថាឲ្យឈប់សម្រាកឲ្យគ្រប់គ្រាន់ ... មិនព្រមស្ដាប់ ធ្វើ ធ្វើទាល់តែល្ងិល្ងើ ឬអង្គុយស្លាប់ ក្នុងកន្លែងធ្វើការ បានជាលោកថា លោភៈ ចាំង អនិច្ចំ។

មានតំណាលថា មនុស្សលោភ១នាក់ បានទៅជួបនឹងព្រះម្ចាស់

អ្នកប្រទានសិទ្ធិ ព្រះម្ចាស់សួរថា អ្នកឯងមានការអី? មនុស្សលោភ ឆ្លើយថា ខ្ញុំចង់បានដី ព្រះម្ចាស់ប្រាប់ថា អ្នកឯងចង់បានប៉ុន្មាន បោះបង្គោល វាស់យកតាមចំណង់ទៅ ។ មនុស្សលោភ គិតថា ដីមានប្រយោជន៍ណាស់ មិនចេះផ្អួមទេ អញត្រូវតែវាស់យកទុកឲ្យច្រើន បោះបង្គោលហើយចាប់រត់តែម្ដង ហត់ហើយ ក៏មិនព្រមឈប់ ចេះតែប្រឹងរត់ រត់ទាល់តែដួល ស្លាប់ ល្ហម ។ ព្រះម្ចាស់ថា ចែកដីឲ្យវា ៤ ហត្ថទៅ ។ នេះ លោក ហៅថា ទុក្ខកើត ព្រោះអញដែរ ។

ទ្រព្យសម្បត្តិ ជារបស់សំខាន់ចាំបាច់ ដែលមនុស្សយើងត្រូវស្វែងរក ត្រូវតែមាន ។ ព្រះពុទ្ធ មិនដែលសម្ដែងធម៌ប្រាប់ឲ្យមនុស្សក្រ ឲ្យមនុស្សខ្ជិលច្រអូសទេ ព្រះអង្គតែងតែសម្ដែងធម៌ប្រាប់ឲ្យគេប្រឹងរកទ្រព្យ ឲ្យគេចេះទុកដាក់ថែរក្សា និង ចាយវាយទ្រព្យឲ្យបានត្រឹមត្រូវសមរម្យផងជាដើម ។ ព្រះពុទ្ធ សម្ដែងបញ្ជាក់ថា ឥណទានំ ទុក្ខំ លោកេ សេចក្ដីខ្វះខាតទីទ័លក្រ ជំពាក់បំណុលគេ ជាទុក្ខលំបាកមួយ ក្នុងលោកនេះ ព្រះអង្គ ទទួលស្គាល់ និង គាំទ្រ ការមានទ្រព្យសម្បត្តិ ដែលស្របតាមច្បាប់ និង គន្លងធម៌ ប៉ុន្តែ ព្រះអង្គសម្ដែងធម៌ឲ្យយើងរៀនគិតឲ្យបានគ្រប់ជ្រុងជ្រោយផងថា-

បុត្តាមត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

មនុស្សល្ងង់ តែងតែក្ដៅក្រហាយថា កូនអញមាន ទ្រព្យអញមាន

តាមសេចក្តីពិត ខ្លួនរបស់ខ្លួនក៏គ្មានផង តើមានកូនមកពីណា មានទ្រព្យមកពីណា? (១១) ។

ហេតុនេះ បើរៀនរឿងលោក ត្រូវរៀនរឿងធម៌ផង បើរៀនរឿងមានអញ ត្រូវរៀនរឿង គ្មានអញ ផង ។

៤- ចិត្តស្ថិតនៅក្នុងភវង្គ ជាចិត្ត បភស្សរៈ មិនស្អប់ មិនស្រឡាញ់ មិនមានអញ មិនមានអត្តា បើប៉ះអារម្មណ៏កាលណា តែភ្លេចអាត្មា អត្តាកើតឡើងភ្លោ អញឪ ... អញម៉ែ ... អញអ្នកស្រែ ... អញអ្នកចំការ ... អញអ្នកផ្សារ ... អញនាម៉ឺន ... អញអ្នកមាន ... អញអ្នកក្រ ... ។ល។ អញឪកើតឡើង មានទុក្ខបែបឪ ... អញអ្នកមានកើតឡើង មានទុក្ខបែបអ្នកមាន ... អញអ្នកក្រកើតឡើង មានទុក្ខបែបអ្នកក្រ ...។ មនុស្សអ្នកក្រ ពេលដែល អញអ្នកក្រមិនទាន់កើតឡើង គេនិយាយសើចលេងសប្បាយក៏បាន ច្រៀងលេងក៏បាន ប៉ុន្តែ លុះពេលណា អញអ្នកក្រកើតឡើង ពេលនោះ គេឈប់សើច ឈប់ច្រៀង គេមុខស្លូត ភ្លួញភ្លែរ រអ៊ូរទាំ មួម៉ៅជាដើម នេះ ទុក្ខកើតព្រោះអញ ។ មនុស្សម្នាក់ៗ ក្នុង១ថ្ងៃ តើអញកើតឡើងប៉ុន្មានដង? បើអញកើតឡើងច្រើន ទុក្ខក៏ច្រើន បើអញកើតឡើងតិច ទុក្ខក៏តិច បើអស់អញ អស់ទុក្ខ ។ ព្រះពុទ្ធត្រាស់ថា អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ លះអស្មិមានះបាន នុ៎ះ ជា

------------------

(១១) សុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋាទិ ៥២/ ១៥/ ៣៤

បរមសុខ ។

៥- អវិជ្ជា តណ្ហា មានះ ទិដ្ឋិ ជាអញ គឺកិលេស គ្រឿងវិលវល់នៃចិត្ត លោកហៅថា កិលេសវដ្តៈ ។ បើចិត្តមានកិលេសគ្រឿងវិលវល់ហើយ តែងតែគិតធ្វើកម្មគឺ អំពើផ្សេង ៗ ជាបុណ្យកុសល ហៅថា បុញ្ញាភិសង្ខារក៏មាន ជាបាបអកុសល ហៅថា អបុញ្ញាភិសង្ខារក៏មាន ជាឈាន ហៅថា អនេញ្ជាភិសង្ខារក៏មាន ។ គំនិតទាំងអស់នេះ ហៅថា កម្មវដ្តៈ គ្រឿងវិលវល់គឺកម្ម (អំពើ) ។ បើមានគ្រឿងវិលវល់គឺកម្មហើយ វិបាកវដ្តៈ គ្រឿងវិលវល់ជាផល គឺ កើត ចាស់ ឈឺ ស្លាប់ ទុក្ខ សោក រោគ ភ័យ មានប្រការផ្សេងៗ នឹងមានតទៅមុខទៀតរកទីបំផុតគ្មាន ។ នេះហើយ លោកហៅថា ទុក្ខកើតព្រោះអញ ។

**គួរធ្វើដូចម្ដេចជាមួយ អត្តា ឬ អញ**

យើងនិយាយថា អត្តា ឬ អញ វាឲ្យទុក្ខច្រើនណាស់ តើយើងត្រូវលះ អត្តា ឬ អញ ឬទេ? ឆ្លើយថា-

១- បើអត្តា ឬ អញ គឺជាអ្វីដែលមិនដឹងជាស្អីផងទេនោះ របស់ពួកមនុស្សល្ងង់ ដែលគេនិយាយស្មានៗតគ្នាមក ដោយមិនមានអ្វីជាពិតប្រាកដ ។ អត្តា ឬ អញរបៀបនេះ មិនត្រូវលះទេ ព្រោះហេតុអ្វី? ព្រោះវាគ្មានអ្វីនឹងលះ យើងលះលុះណាតែវត្ថុនោះ ឬ សភាវៈនោះវាមាន ចុះបើវាគ្មានផង តើលះអី បានអីលះ មិនបាច់លះទេរបស់ដែលគ្មានស្រាប់ទៅហើយនោះ ។

២- បើអត្តា ឬ អញ សំដៅយកខន្ធប្រាំគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ។ អត្តា ឬ អញ របៀបនេះ ចាត់ជា ទុក្ខសច្ច ជារបស់ត្រូវកំណត់ដឹងឲ្យច្បាស់ តាមសភាវៈពិត ជារបស់មិនត្រូវលះទេ ប៉ុន្តែត្រូវលះឆន្ទរាគៈ សេចក្តីត្រេកត្រអាល ពេញចិត្ត ក្នុងខន្ធប្រាំនោះ(១២) ។

ខន្ធប្រាំ ជាវិបាកនៃកម្មចាស់ បុថុជ្ជន ក៏មានខន្ធប្រាំ ព្រះអរិយៈក៏មានខន្ធប្រាំដូចគ្នា ប្លែកគ្នាត្រង់ បុថុជ្ជន មានឆន្ទរាគៈក្នុងខន្ធប្រាំ ព្រះ-អរិយៈមិនមានឆន្ទរាគៈ ក្នុងខន្ធប្រាំទេ បុថុជ្ជន មានទុក្ខ ២ ជាន់ គឺ ទុក្ខនៃខន្ធប្រាំដែលមាន អនិច្ចំ ទុក្ខំ អនត្តា ផង ទុក្ខនៃចិត្ត ដែលសោកស្តាយ កន្ទក់កន្ទេញ ព្រោះខន្ធប្រាំមិនប្រព្រឹត្តទៅតាមបំណងរបស់ខ្លួនផងឯព្រះអរិយៈ មានទុក្ខតែ ១ជាន់ គឺ ទុក្ខនៃខន្ធប្រាំតែប៉ុណ្ណោះ ។

៣- បើអត្តា ឬ អញ សំដៅយកកិលេសគឺ ទិដ្ឋិ មានៈ តណ្ហា និង អវិជ្ជា ។ អត្តា ឬ អញរបៀបនេះ ចាត់ជា ទុក្ខសមុទយសច្ច ជាហេតុនាំឲ្យកើតទុក្ខ ត្រូវតែលះបង់ដោយមិនមានលក្ខខ័ណ្ឌអ្វីទាំងអស់ ។

**តើលះ អត្តា ឬ អញ ដោយវិធីដូចម្តេច ?**

អត្តា ដែលមិនដឹងជាអ្វីទេនោះ វាចប់ហើយ មិនមានអ្វី នឹងត្រូវលះទេ។ អត្តា ដែលជាតួ បញ្ចក្ខន្ធ ក៏មិនត្រូវលះដែរ ។ នៅសល់តែ អត្តា ដែលជាតួកិលេស ទើបត្រូវលះបង់ តើលះបង់ ដោយវិធីដូចម្តេច?

---

(១២) សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ៣៤/ ៦៤/ ៤៩

កិលេសជានាមធម៌ គ្មានរូបរាងទេ កើតឡើងនៅក្នុងចិត្ត វាធ្វើចិត្តឲ្យសៅហ្មង ឲ្យប្រឡាក់ ឲ្យអាក្រក់ ឲ្យកើតសេចក្តីទុក្ខលំបាក ប្រៀបដូចជាមេរោគដែលកើតនៅក្នុងកាយ ហើយធ្វើកាយឲ្យមានទុក្ខលំបាកដូចនោះដែរ។ កិលេសកើតឡើង ក្នុងកន្លែងណា ត្រូវព្យាបាលត្រូវលះបង់ក្នុងកន្លែងនោះ វារលត់ទៅ ក្នុងកន្លែងនោះ ។ កិលេសកើតឡើងក្នុងចិត្ត ត្រូវព្យាបាល ត្រូវលះបង់ក្នុងចិត្តនោះឯង ។ ចិត្ត មានអវិជ្ជា មានទិដ្ឋិ មានមានៈ មានតណ្ហា ត្រូវលះបង់ អវិជ្ជា ទិដ្ឋិ មានៈ តណ្ហា នោះ ត្រូវដុះខាត់ ត្រូវលាងសំអាត ត្រូវជម្រុះកិលេសដែលមានហើយនោះ បោលចេញ និង ត្រូវការពារទប់ទល់ កុំឲ្យកិលេសថ្មីកើតឡើងទៀតបាន ។ ចិត្ត មានអវិជ្ជា សេចក្តីមិនដឹងច្បាស់ យល់ឃើញថា មានអត្តា ឬ អញ នៅក្នុងបញ្ចក្ខន្ធ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ឬ យល់ឃើញថា បញ្ចក្ខន្ធ ជាតួ អត្តា ឬ អញ ត្រូវបណ្តុះវិជ្ជា សេចក្តីដឹងច្បាស់ឲ្យ កើតឡើងក្នុងចិត្ត ធ្វើចិត្តឲ្យយល់ច្បាស់ថា បញ្ចក្ខន្ធ ជាអ្វី រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាអ្វី កើតឡើងដោយវិធីណា រលត់ទៅ ដោយ-វិធីណា មានគុណ ដូចម្តេច មានទោសដូចម្តេច រលាស់បោល បាន ដោយវិធី ដូចម្តេច? កាលបើ គេបានដឹងច្បាស់នូវបញ្ចក្ខន្ធ ដឹងច្បាស់ នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គេអស់អត្តា អស់អញហើយ ។ នេះជាវិធីលះអត្តា ឬ អញដោយសង្ខេប ។ ដឹងច្បាស់ មិនមែនមាត់ ដឹងទេ មិនមែនខួរក្បាលដឹងទេ តែចិត្តអ្នកដឹងច្បាស់ ដឹងច្បាស់ មិនដូច

ដឹង មិនឃើញ ទេ ។

ម្នាលភិក្ខុទាំងឡាយ សមណៈ ឬ ព្រាហ្មណ៍ ណាមួយ មិនដឹងច្បាស់តាមពិតនូវសមុទយៈ សេចក្តីកើតឡើងផង អត្ថង្គមៈ សេចក្តីរលត់ទៅផង អស្សាទៈ គុណផង អាទីនវៈ ទោសផង និស្សរណៈ ការរលាស់ចេញផង នៃឧបាទានក្ខន្ធទាំង ៥ នេះ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មិនសន្មត សមណៈ ឬព្រាហ្មណ៍ នោះថាជា សមណៈក្នុងពួកសមណៈ ថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ ឡើយ ។ សមណៈ ឬ ព្រាហ្មណ៍នោះ រមែងមិនធ្វើឲ្យ ជាក់ច្បាស់ ដោយប្រាជ្ញា ដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬ ប្រយោជន៍នៃព្រាហ្មណភាពទេ ។

ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ ណាមួយ ដឹងច្បាស់តាមពិត នូវសមុទយៈ សេចក្តីកើតឡើងផង អត្ថង្គមៈ សេចក្តីរលត់ទៅផង អស្សាទៈ គុណផង អាទីនវៈ ទោសផង និស្សរណៈ ការរលាស់ចេញផង នៃឧបាទានក្ខន្ធទាំង ៥ នេះ ។

ម្នាលភិក្ខុទាំងឡាយ តថាគត សន្មត សមណៈឬព្រាហ្មណ៍នោះ ថាជា សមណៈក្នុងពួកសមណៈ ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ ។ សមណៈ ឬ ព្រាហ្មណ៍នោះ រមែងធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬ ប្រយោជន៍

នៃព្រាហ្មណភាពបាន (១៣) ។

ព្រះរាហុលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលកាលដឹងដូចម្តេច ឃើញដូចម្តេច បានជាមានចិត្តប្រាសចាក អហង្ការ មមង្ការ និង មានះ ក្នុងកាយប្រកបដោយវិញ្ញាណ នេះផង ក្នុងនិមិត្តទាំងពួងខាងក្រៅផង ជាចិត្តប្រព្រឹត្តកន្លងដោយប្រពៃនៃមានះ ស្ងប់រម្ងាប់ផុតស្រឡះហើយ ។

ម្នាលរាហុល រូប ណានីមួយ ជាអតីតៈក្តី អនាគតក្តី បច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាប ក្តី ឧត្តមក្តី ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះ ឈ្មោះថា ជារូប បុគ្គលឃើញនូវរូបនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះ ថានុ៎ះមិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះ មិនមែនជាខ្លួន របស់អញ ដូចនេះហើយ ទើបបានរួចស្រឡះចាកកិលេស ព្រោះមិនមានសេចក្តីប្រកាន់ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ មានអត្ថន័យ ដែលបុគ្គលគប្បីជ្រាប ដូចគ្នានឹងរូបដែរ(១៤) ។ ព្រះកប្បៈ ទូលសួរដូចគ្នា នឹងព្រះរាហុលដែរ ។

---

(១៣) សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ៣៤/ ២២/ ៨

(១៤) សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ ៣២/ ៣០២/ ២៣៦
សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ៣៤/ ៤៥/ ២៨

ព្រះរាធៈ ទូលសួរ ព្រះសម្មាសម្ពុទ្ធថា-

បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា មារ មារ តើដោយហេតុដូចម្តេច? ព្រះពុទ្ធ ឆ្លើយថា ម្នាលរាធៈ អ្នកចូរឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាមារ ជារោគ ជាបូស ជាសរ ជាទុក្ខ ជារបស់មានទុក្ខ ពួកជនណាឃើញយ៉ាងនេះ ជននោះ ឈ្មោះថា ឃើញដោយប្រពៃ ។ ឃើញដោយប្រពៃ មានប្រយោជន៍អ្វី? ព្រះអង្គ ។ មានប្រយោជន៍ឲ្យកើត និព្វិទា សេចក្តីនឿយណាយ ។ នឿយណាយមានប្រយោជន៍អ្វី? ព្រះអង្គ ។ មានប្រយោជន៍ឲ្យកើត វិរាគៈ សេចក្តីប្រាសចាកតម្រេក ។ ប្រាសចាក តម្រេក មានប្រយោជន៍អ្វី? ព្រះអង្គ ។ មានប្រយោជន៍ឲ្យបានវិមុត្តិ សេចក្តីរួចផុតស្រឡះ ។ សេចក្តីរួចផុតស្រឡះ មានប្រយោជន៍អ្វី? ព្រះអង្គ ។ មានប្រយោជន៍ឲ្យបានសម្រេចព្រះនិព្វាន។ និព្វាន មានប្រយោជន៍អ្វី? ព្រះអង្គ ។ លោកសួរហួសបញ្ហាហើយ មិនអាចកាន់យក ទីបំផុតនៃបញ្ហាបានឡើយ ។ ម្នាលរាធៈ ការប្រព្រឹត្តិ - ព្រហ្មចរិយធម៌ មានការទោរទាបទៅរក ព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត(១៥) ។

ព្រះរាធៈ ទូលសួរ ព្រះសម្មាសម្ពុទ្ធថា

បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា សត្វ សត្វ តើដោយ ហេតុដូចម្តេច?

---------------------

(១៥) សុត្តន្តបិដក សំយុត្តនិកាយ មារវគ្គ ៣៤/ ៩៣/ ៧១

ព្រះពុទ្ធ ឆ្លើយថា ម្នាលរាធៈ សេចក្តីពេញចិត្ត សេចក្តី ត្រេកត្រអាល សេចក្តីរីករាយ សេចក្តីប្រាថ្នា ក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បុគ្គលដែលជាប់ជំពាក់ ក្នុងសេចក្តីពេញចិត្តជាដើម ក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នោះ លោកហៅថា សត្វ ។ ម្នាលរាធៈ ដូច ពួកកុមារក្តី ពួកកុមារីក្តី នាំគ្នាលេងកូនផ្ទះធ្វើពីអាចម៍ដី មិនទាន់ប្រាស ចាកតម្រេក មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ ប្រាសចាក សេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាក សេចក្តីឆ្អើឆ្អា មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកូនផ្ទះធ្វើពី អាចម៍ដី ទាំងនោះ ដរាបណា តែងអាល័យ តែងប្រកាន់លេង តែងប្រកាន់ថាជា ទ្រព្យ ប្រកាន់ថាជារបស់ខ្លួន ចំពោះកូនផ្ទះធ្វើពីអាចម៍ដី ដរាបនោះ ។

ម្នាលរាធៈ កាលបើពួកកុមារក្តី ពួកកុមារីក្តី លែងត្រេក ត្រអាល លែងពេញចិត្ត លែងស្រឡាញ់ លែងស្រេកឃ្លាន លែងឆ្អើឆ្អា លែងប្រាថ្នា ក្នុងកូនផ្ទះ ធ្វើពីអាចម៍ដីទាំងនោះ ហើយ យកដៃ និងជើង ទៅកំចាយ ចោល ឈូសចោល កំចាត់ចោល នូវកូនផ្ទះធ្វើពីអាចម៍ដី ទាំងនោះ ធ្វើ ឲ្យជារបស់លេងមិនកើត ក្នុងកាលនោះ យ៉ាងណាមិញ ។

ម្នាលរាធៈ អ្នកទាំងឡាយ ចូលកំចាយចោល ឈូសចោល កំចាត់ចោល នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ចូរធ្វើឲ្យជារបស់ លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា យ៉ាងនោះឯង ។

ម្នាលរាធៈ ព្រោះថា ការអស់ទៅនៃតណ្ហា ឈ្មោះថាព្រះនិព្វន(១៦) ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវឆន្ទៈ សេចក្តីពេញចិត្ត នូវរាគៈ សេចក្តីត្រេកត្រអាល នូវនន្ទិ សេចក្តីរីករាយ នូវតណ្ហា សេចក្តីប្រាថ្នាក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណចេញ កាលបើ យ៉ាងនេះ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនោះនឹងជារបស់ដែលអ្នក លះបាន ហើយ កាត់ឫសដាច់ហើយ ធ្វើឲ្យដូចជា ដើមត្នោតកំបុតចុង ធ្វើមិនឲ្យមាន មិនឲ្យកើតតទៅទៀតបានជាធម្មតា ។ ការលះបង់នូវតណ្ហាក្នុងរូបជាដើមនោះ ឈ្មោះថាព្រះនិព្វន(១៧) ។

ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន សម្តែងធម៌ថា ភិក្ខុអ្នកឆ្លាតក្នុងឋានៈ៧ប្រការ ពិនិត្យពិចារណាដោយវិធី ៣ ប្រការ តថាគតហៅថា ឧត្តមបុរស ជាកំពូល ជាអ្នកចប់ព្រហ្មចរិយធម៌ហើយ ក្នុងធម៌វិន័យនេះ។

ឆ្លាតក្នុងឋានៈ ៧ ប្រការគឺឆ្លាតក្នុងខន្ធ ៥ ដោយឋានៈ ៧ប្រការគឺ

១- រូបំ បជានាតិ ដឹងច្បាស់នូវរូប ។

២- រូបសមុទយំ បជានាតិ ដឹងច្បាស់នូវហេតុកើតឡើងនៃរូប ។

៣- រូបនិរោធំ បជានាតិ ដឹងច្បាស់នូវការរលត់ទៅនៃរូប ។

--------------------

(១៦) សុត្តន្តបិដក សំយុត្តនិកាយ មារវគ្គ ៣៤/ ៩៤/ ៧៣

(១៧) សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ៣៤/ ២៥/ ១០

៤- រូបនិរោធគាមិនីបដិបទំ បជានាតិ ដឹងច្បាស់នូវបដិបទាជាទី
វំលត់ទៅនៃរូប ។

៥- រូបស្ស អស្សាទំ បជានាតិ ដឹងច្បាស់នូវគុណនៃរូប ។

៦- រូបស្ស អាទីនវំ បជានាតិ ដឹងច្បាស់នូវទោសនៃរូប ។

៧- រូបស្ស និស្សរណំ បជានាតិ ដឹងច្បាស់នូវការរលាស់ចេញនៃរូប។

ឆ្ពាតក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ៧ ប្រការ មានអត្ថន័យដូចគ្នានឹងរូបដែរ ។

រូបគឺអ្វី? គឺមហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ នោះ ។ រូបកើតឡើងព្រោះអាហារ , រលត់ទៅវិញព្រោះអាហារ , ឯបដិបទាជាទីរលត់ទៅនៃរូប គឺអដ្ឋង្គិកមគ្គ , សុខសោមនស្សដែលអាស្រ័យរូបកើតឡើង ចាត់ជាគុណរបស់រូប , រូបជាអនិច្ចំ ទុក្ខំ អនត្តា ទុកជាទោសរបស់រូប , ការលះ សេចក្តីពេញចិត្តក្នុងរូបចេញបាន នេះជាការរលាស់ចេញនៃរូប ។

វេទនា គឺ វេទនា ៦ ដែលកើតឡើងអាស្រ័យ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជីវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស ។ វេទនា កើតឡើងព្រោះផស្សៈ ។ សេចក្តីអធិប្បាយ គប្បីយល់តាមទំនងនៃរូប ។

សញ្ញា ៦ គឺ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា ។ សញ្ញា កើតឡើង ព្រោះផស្សៈ ។

សេចក្តីអធិប្បាយ គប្បីយល់តាមទំនងនៃរូប ។

សង្ខារ ៦ គឺ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា ។ សង្ខារ កើតឡើង ព្រោះផស្សៈ ។ សេចក្តីអធិប្បាយ គប្បីយល់ តាមទំនងនៃរូប ។

វិញ្ញាណ ៦ គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ។ វិញ្ញាណ កើតឡើង ព្រោះ នាមរូប , រលត់ទៅវិញព្រោះ នាមរូប , ឯបដិបទាជាទីរលត់ទៅនៃ វិញ្ញាណគឺ អដ្ឋង្គិកមគ្គ ។ សុខសោមនស្សដែលអាស្រ័យវិញ្ញាណកើតឡើង ចាត់ជាគុណរបស់វិញ្ញាណ, វិញ្ញាណ ជាអនិច្ចំ ទុក្ខំ អនត្តា ទុកជា ទោសរបស់វិញ្ញាណ , ការលះ សេចក្តីពេញចិត្តក្នុងវិញ្ញាណចេញបាន នេះជាការរលាស់ចេញនៃវិញ្ញាណ។

សមណព្រាហ្មណ៏ ណាមួយ ដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ យ៉ាងនេះ ដឹងច្បាស់នូវហេតុកើត ហេតុរលត់ បដិបទា ជាទីរលត់ គុណ ទោស និងការរលាស់ចេញនៃ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណយ៉ាងនេះ ហើយបដិបត្តិដើម្បីសេចក្តីនឿយណាយ ដើម្បី ប្រាសចាកតម្រេក ដើម្បីរលត់ (នូវរូប វេទនា ។ល។ ) សមណ ព្រាហ្មណ៏ នោះ ឈ្មោះថា បដិបត្តិ ទោរទន់ទៅក្នុងធម៌វិន័យ នេះ ។

សមណព្រាហ្មណ៏ ណាមួយ ដឹងច្បាស់នូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ យ៉ាងនេះ ដឹងច្បាស់នូវហេតុកើត ហេតុរលត់ បដិបទា

ជាទីរលត់ គុណ ទោស និង ការរលាស់ចេញនៃ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ យ៉ាងនេះ ហើយបដិបត្តិ រួចផុតហើយ ព្រោះសេចក្តីនឿយណាយ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ ព្រោះមិនប្រកាន់មាំនូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ សមណព្រាហ្មណ៍នោះ ឈ្មោះថា រួចផុតល្អហើយ ។ សមណព្រាហ្មណ៍ ឯណា រួចផុតល្អហើយ សមណព្រាហ្មណ៍នោះ ចប់កិច្ចហើយ មិនមានវដ្តៈប្រាកដទៀតទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិនិត្យពិចារណា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយវិធី ៣ ប្រការគឺ ដោយពិចារណា ខន្ធប្រាំថាជាធាតុ ១ ដោយពិចារណាខន្ធប្រាំថាជាអាយតនៈ ១ ដោយពិចារណាខន្ធប្រាំថាជាបដិច្ចសមុប្បាទ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ហៅភិក្ខុ អ្នកឆ្លាតក្នុងឋានៈ ៧ ប្រការ និង ពិនិត្យពិចារណា ដោយវិធី ៣ ប្រការនេះថា ជាឧត្តមបុរស ជាកំពូល ជាអ្នកចប់ព្រហ្មចរិយធម៌ហើយ (១៨) ។

ខ្ញុំបានដកស្រង់ខ្លះៗនូវពុទ្ធវចនៈខ្លីៗ ស្តីពីសេចក្តីដឹងច្បាស់ តាមសេចក្តីពិត ជូនលោក អ្នកអាន ដើម្បីសិក្សា ពិចារណា បដិបត្តិ តាមលទ្ធភាពរៀងៗខ្លួន។ ខ្ញុំសូមរំលឹកថា ពាក្យនេះងាយស្តាប់ទេ ប៉ុន្តែ ពិបាកយល់ឲ្យដល់ជម្រៅរបស់វា ហើយក៏ពិបាកជាងនេះទៅទៀត នឹងធ្វើវាឲ្យ

------------------

(១៨) សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវារវគ្គ ៣៣/ ១១៨/ ១៤២

កើតឡើងបាន ។ ដឹងច្បាស់ ដឹងដូចម្តេច ហៅថា ដឹងច្បាស់? ដឹងច្បាស់ គឺដឹងដោយភាវនាមយបញ្ញា មិនមែនដឹងដោយ សុតាមយបញ្ញា ឬ ចិន្តាមយបញ្ញាទេ ។ ដឹងច្បាស់ សេចក្តីអាក្រក់ត្រូវថយចុះ សេចក្តីល្អត្រូវកើតឡើង បើមិនដូចនោះទេ មិនមែនសេចក្តីដឹងច្បាស់ទេ ។ ដឹងច្បាស់ មិនមែនមានតែមួយកម្រិតទេ គឺមានច្រើនកម្រិត ខ្ពស់ឡើងៗ ជាលំដាប់រហូតដល់កាត់សេចក្តីអាក្រក់អស់ទាំងស្រុងបាន ។ តាមសេចក្តីពិតដូចម្តេចហៅថា តាមសេចក្តីពិត? សេចក្តីពិតរបស់យើងផ្សេង សេចក្តីពិតរបស់វាផ្សេង ។ សេចក្តីពិតរបស់យើងមាន មនុស្ស សត្វ ខ្មែរ យួន សៀម។ល។ សេចក្តីពិតរបស់វាមិនមាន មនុស្ស សត្វ ខ្មែរ យួន សៀម ។ល។ ទេ មានតែធាតុ ៤ ខន្ធ ៥ ជាដើមតែប៉ុណ្ណោះ ។ ពាក្យថា ដឹងច្បាស់តាមសេចក្តីពិត ក្នុងទីនេះ សំដៅយកសេចក្តីពិតរបស់វា មិនមែនសេចក្តីពិតតាមដែលយើងនាំគ្នាសន្មតនោះទេ ។

តើយើងធ្វើដូចម្តេច ដើម្បីឲ្យកើតសេចក្តីដឹងច្បាស់ តាមសេចក្តីពិតនោះ ។ វាពិបាកណាស់ ពិបាកនៅត្រង់ណឹង ។ វិធីបដិបត្តិឲ្យកើតសេចក្តីដឹងច្បាស់ តាមសេចក្តីពិត ចែកជា២ ដំណាក់ការគឺ ដំណាក់ការទី១ យើងត្រូវហ្វឹកហាត់បណ្តុះឲ្យមានសតិសម្បជញ្ញៈ ដឹងទាន់នូវសេចក្តីពិតគ្រប់សកម្មភាពរបស់យើង សកម្មភាពការងារក្តី សកម្មភាពរាងកាយក្តី សកម្មភាពផ្លូវចិត្តក្តី ក្នុងជីវិតប្រចាំថ្ងៃ ។ ដំណាក់ការទី២ យើងត្រូវតែចូលទៅហ្វឹកហាត់អប់រំចិត្ត ក្នុងមណ្ឌលណាមួយ តាមកំណត់កាលដ៏សមគួរ

ដើម្បីអប់រំចិត្តយើងឲ្យកើតសេចក្តីស្ងប់ខ្លះ ។ អាស្រ័យសេចក្តីស្ងប់ខ្លះនោះជាដើមទុន យើងបណ្តុះ បញ្ញា សេចក្តីដឹងច្បាស់ឲ្យកាន់តែច្បាស់ឡើង ។ ថែមទៀត ជាលំដាប់ ។ វិធីបដិបត្តិទាំង ២ ដំណាក់ការនេះ ត្រូវតែ អាស្រ័យគ្នា មិនគប្បីធ្វើមួយចោលមួយឡើយ បើចោលណាមួយហើយនឹងមិនសម្រេចផល ជាទីគាប់ចិត្តទេ ។ ហេតុនេះ បើមានឱកាស យើងគួរចូលទៅធ្វើការអប់រំបន្ទុំនិស្ស័យក្នុងមណ្ឌលណាមួយ ឬ បើយើងមានការចេះដឹងច្រើនហើយ គួរជ្រើសរើសរកសេនាសនៈស្ងាត់ណាមួយ ជាកន្លែងអប់រំចិត្ត ធ្វើការអប់រំចិត្តជាពិសេស ១រយៈកាលដ៏សមគួរ ក្រោយពីការអប់រំពិសេសនោះ យើងវិលមកអប់រំក្នុងជីវិតប្រចាំថ្ងៃ នៅផ្ទះរបស់យើងតទៅទៀត ។ វិធីបដិបត្តិទាំង ២ ដំណាក់ការនេះហើយ ដែលជួយយើងឲ្យកើត បញ្ញាដឹងច្បាស់ឡើង ។ តាមសេចក្តីពិតជាលំដាប់ រហូតដល់អស់កិលេសអស់អញទៅបាន ។ លោក អ្នកមានសទ្ធាជ្រះថ្លា ត្រូវការបដិបត្តិ អញ្ជើញរកក្បួនខ្នាតនិងមណ្ឌលអប់រំ សមតាមអាធ្យាស្រ័យរបស់ខ្លួនផងចុះ ។

## អស់អញ ដោយឈប់និយាយ

បុគ្គលខ្លះ គេខ្លាចមានអត្តាមានអញ គេមិនហ៊ាននិយាយ ថាខ្លួនថាខ្ញុំ ខ្ញុំទៅវត្ត... ខ្ញុំធ្វើការ... ដូចនេះជាដើមទេ គេថា បើនិយាយអីចឹងទៅ វាជាប់អត្តាជាប់អញហើយ ដូចនេះដើម្បីឲ្យអស់អត្តាអស់អញ ត្រូវតែឈប់និយាយថាអញថាខ្ញុំ ព្រោះវាគ្មានអញគ្មានខ្ញុំឯណាទេ វាមានតែខន្ធ ៥

ប៉ុណ្ណោះ ។ នេះ ទិដ្ឋិចម្លែក ទិដ្ឋិបង្គួរឿង ។ បើគ្រាន់តែឈប់និយាយថាអញថាខ្ញុំ ហើយវាអស់អញមែន មនុស្សគប្រហែលជាអស់អញហើយ ។ អញវាមិនជាប់នៅនឹងមាត់ទេ វាជាប់នៅនឹងចិត្ត ត្រូវផុះខាត់ចិត្ត ត្រូវជម្រះកិលេសក្នុងចិត្តចេញ ធ្វើចិត្តកុំឲ្យជាប់ជំពាក់ ។

ព្រះពុទ្ធ សម្ដែងថា តថាគតមិនទំនាស់នឹងលោកទេ តែលោកទំនាស់នឹងតថាគត... ។ តថាគត កើតក្នុងលោក តែមិនជាប់លោកទេ ដូចផ្កាឈូកកើតក្នុងទឹក តែមិនជាប់ទឹកដូចនោះ (១៩) ។

ព្រះពុទ្ធ ត្រាស់ថា ម្នាលអគ្គិវេស្សនៈ ភិក្ខុអ្នកមានចិត្តផុតស្រឡះហើយរមែងមិនឈ្លោះទាស់ទែងនឹងនរណា វោហារណា ដែលមនុស្សលោកគេនិយាយ ក៏និយាយវោហារនោះជាមួយនឹងគេ ប៉ុន្តែ មិនប្រកាន់មាំដោយទិដ្ឋិ (២០) ។

## អស់អញ មិនធ្វើការងារ

បុគ្គលខ្លះគេយល់ថា មនុស្សយើងបើអស់អញ(ទិដ្ឋិ មានះ) អស់របស់អញ(តណ្ហា) លែងធ្វើការងារហើយ ។ សព្វថ្ងៃ មនុស្សយើង ខំធ្វើការងារព្រោះមានអញមានរបស់អញ បើវាអស់អញ អស់របស់អញរលីងទៅហើយ ខំធ្វើការងារធ្វើអ្វីទៀត ធ្វើឲ្យនរណា ត្រូវតែឈប់ធ្វើការទៅ ។

-------------------

(១៩) សុត្តន្តបិដក សំយុត្តនិកាយ ខន្ធសំយុត្ត មជ្ឈិមបណ្ណាសក ៣៣/ ២៤១/៣១៩
(២០) សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ទីឃនខសូត្រ ២៤/ ៣៤/៥៦

បើមនុស្សឈប់ធ្វើការ មនុស្សលោកនឹងធ្លាក់ខ្លួនទៅជាក្រីក្រ ពិភពលោក មិនចំរើន មានបញ្ហាធំហើយ ។

មនុស្សល្ងង់(អវិជ្ជា) មនុស្សល្មោភ(តណ្ហា) គិតឃើញអីចឹង យល់ឃើញអីចឹង ហើយវាអាចនឹងទៅជាយ៉ាងណឹងតាមបែបដែលមនុស្សល្ងង់គិតនោះមែន ប្រសិនបើមនុស្សល្ងង់លង់លក់នៅក្នុង អវិជ្ជា តណ្ហានោះ។ ប៉ុន្តែ បើមនុស្សយើងចេះរំដោះខ្លួនឲ្យរួចផុតពីអវិជ្ជា តណ្ហាបាន គេនឹងមានគំនិតភ្លឺស្វាង គេនឹងអាចសាងសេចក្តីសុខ ត្រជាក់ត្រជុំក្សេមក្សាន្តបាន មិនមែនដូចជាការប៉ាន់ស្មានរបស់ពួកមនុស្សល្ងង់នោះទេ ។

សូមយើងសង្កេតមើល ពិចារណាមើល មនុស្សយើងមាន ២ បែប បុគ្គលខ្លះធ្វើការងារដោយសារអវិជ្ជា តណ្ហា សូម្បីតែធ្វើបុណ្យ ក៏ប្រើអវិជ្ជា តណ្ហាដែរ បើគេប្រកាសសរសើរ ឬ បញ្ជោរដាក់មេក្រូ សប្បាយណាស់ ជ្រះថ្លាណាស់... ។ មនុស្ស អ្នកប្រកបការងារដោយអវិជ្ជា តណ្ហា មិនសូវមានសេចក្តីស្មោះត្រង់ មិនសូវមានមេត្តា ករុណា ពិតប្រាកដទេ សូម្បីគេយកច្បាប់គាបតម្រង់យ៉ាងណា ក៏នៅតែមិនសូវត្រង់ គេនៅតែរកឧបាយបំប៉ិនបំប៉ោងអាត្មាគេ ហើយសង្កត់សង្កិនអ្នកដទៃដដែល ។ សេចក្តីចំរើនដែលមាន អវិជ្ជា តណ្ហា ជាអ្នកនាំមុខ មិនអាចធានាបាននូវសេចក្តីសុខក្សេមក្សាន្តត្រជាក់ត្រជុំដល់សង្គមមនុស្សជាស្ថាពរទេ វាតែងតែបង្កទុក្ខទោសផ្សេងៗ រៀងរាល់ថ្ងៃ ហើយតទៅមុខវានឹងផ្តល់ទុក្ខទោសយ៉ាងធ្ងន់ថែមទៀតជាមិនខាន ។ បុគ្គលខ្លះទៀត គេធ្វើការងារមិនយកអវិជ្ជា តណ្ហានាំមុខទេ

គេធ្វើការងារដោយសារ បញ្ញា និង មេត្តា ករុណាធម៌ ។ គុណធម៌នេះហើយ នាំគេឲ្យធ្វើការ ធ្វើការដើម្បីខ្លួនផង ដើម្បីអ្នកដទៃផង ឬថាដើម្បីសព្វសត្វផង ដូចនេះក៏បាន មិនមែនធ្វើការដើម្បីបំពេញអាត្មាអញ ឬពួកបក្សគណៈអញទេ ។ បើពិតជាមនុស្សស្រាលអញ ឬ អស់អញមែនគេមិនខ្ជិលច្រអូស មិនឈប់ធ្វើការងារទេ មានព្រះពុទ្ធជាតួយ៉ាងស្រាប់ ។ ព្រះពុទ្ធទ្រង់បំពេញពុទ្ធកិច្ចយ៉ាងច្រើន ដែលមនុស្សសាមញ្ញមិនអាចធ្វើតាមបាន មិនមែនដោយសារមានអញ មានរបស់អញទេ គឺពិតជាដោយសារព្រះបញ្ញាញាណ និង ព្រះមហាមេត្តាករុណាទិគុណជាដើមតែប៉ុណ្ណោះ ។ ហេតុនេះ កុំនាំគ្នាព្រួយបារម្ភថា បើមនុស្សអស់អញ មិនធ្វើការងារនោះឲ្យសោះ ។ ចូរនាំគ្នាបន្ថយអញឲ្យបានច្រើនទៅ នឹងកើតបញ្ញានាំផ្លូវទៅរកសុខសន្តិភាពពិតប្រាកដជាពុំខាន ។

## អស់អញ មមិងមមាំង

បុគ្គលខ្លះនិយាយថា មនុស្សយើងបើអស់អញ ក្រែងទៅជាមមិងមមាំង ឡប់ៗ ឡីកឺ ស្ទើរតែយកជាការអីមិនកើតទេដឹង ។ និយាយអីចឹងវាមិនត្រូវតាមច្បាប់ហេតុផលសោះ មនុស្សអ្នកអប់រំចិត្ត អ្នកហ្វឹកហាត់សតិសម្បជញ្ញៈ អ្នកស្រាលអញ អ្នកអស់អញ ទៅជាមមិងមមាំង ចុះអ្នកមិនអប់រំចិត្ត... នៅអញពេញដើមទ្រូង តើវាយ៉ាងម៉េចទៅវិញ ។ អ្នកមិនអប់រំចិត្ត អ្នកមានអញពេញដើមទ្រូង គេមិនសូវគិតវែងឆ្ងាយ បាបបុណ្យគុណទោសទេ ធ្វើយ៉ាងម៉េចឲ្យតែគេបានគេមាន ឲ្យតែគេបាន

សប្បាយតាមចិត្តគេចង់ គឺវាគ្រប់ទឹកហើយ ត្រង់អ្នកឯទៀតទុក្ខលំបាកឯណាគេមិនសូវរវល់គិតទេ បើមានគិតខ្លះ ច្រើនតែធ្វើជាឡប់ឡែកែរកប្រយោជន៍ ឬ ប្រជាភិថុតិតែប៉ុណ្ណោះ ។ គេគិតតែពីសប្បាយ សប្បាយពេកទៅ ប្រព្រឹត្តថោកទាបជាងសត្វតិរច្ឆានក៏មានដែរ ។ ឯអ្នកអប់រំចិត្ត... អ្នកអស់អញ គេធ្វើអ្វីសុទ្ធតែមានហេតុផល គេមិនធ្វើតាមតែទម្លាប់ តាមតែចូលចិត្តនោះទេ បើគេសប្បាយ ក៏សប្បាយបែបមានសតិសម្បជញ្ញៈ សប្បាយយ៉ាងរៀបរយសមរម្យ ។ យើងឃើញគេធ្វើអ្វីមិនដូចយើង យើងថាគេមមិងមមាំង មិនគិតប្រយោគមើលខ្លួនឯងខ្លះផង ។

មនុស្សមមិងមមាំងមានខ្លះដែរ ប៉ុន្តែ មិនមែនអ្នកអស់អញទេ ។ បុគ្គលខ្លះ បែបមមិងមមាំង តាំងពីមុនចូលបដិបត្តិធម៌មកម៉្លេះ ។ ឬក៏អ្នកខ្លះបដិបត្តិធម៌តៗគ្នាអត់គិតពិចារណារកហេតុផល បដិបត្តិទាំងងឹតងងល់ មិនយល់ធម៌ពិតធម៌មែន ពួកនេះអាចឡប់ៗខុសធម្មតាទៅក៏មានដែរ ។ ការបាន់ស្មាន បួកម៉ៅ ហើយនិយាយប្រមាថប៉ះទៅលើមនុស្សល្អ ចាត់ជាអំពើអកុសលមួយ ដែលអ្នកមានសតិសម្បជញ្ញៈ គេមិននិយមធ្វើឡើយ ។

## ទុក្ខកើតព្រោះអញ ឬ ព្រោះតណ្ហា?

បើនិយាយតាមអ្នកស្រុក ហេតុនាំឲ្យកើតទុក្ខមានច្រើនណាស់ ក្រទ្រព្យសម្បត្តិ ជាហេតុនាំឲ្យកើតទុក្ខ , មានរោគាព្យាធិ ជាហេតុនាំឲ្យកើតទុក្ខ , អត់សក្តិយស ជាហេតុនាំឲ្យកើតទុក្ខ , រូបមិនល្អ ជាហេតុនាំឲ្យកើតទុក្ខ ។ល។ បើនិយាយឲ្យខ្លីតាមទ្រឹស្តី អរិយសច្ច របស់ព្រះពុទ្ធ

ហេតុនាំឲ្យកើតទុក្ខគឺ តណ្ហា ។ ចុះ ទុក្ខកើតព្រោះអញ មកពីណាមក? ឆ្លើយថា ទុក្ខ កើតព្រោះអញគឺ អហង្ការ ក៏ជាទ្រឹស្តីរបស់ព្រះពុទ្ធដែរ តែនិយាយពង្រីក សេចក្តីឲ្យងាយស្តាប់ ។ អហង្ការ ប្រកាន់ថាអញ ឯសោហមស្មិ ន៑ុះ ជាអញ ឯសោ មេ អត្តា ន៑ុះ ជាខ្លួនរបស់អញ ។ ទុក្ខកើតព្រោះតណ្ហាគឺ មមង្ការ ប្រកាន់ថា របស់អញ ឯតំ មម ន៑ុះ របស់អញ ជាទុក្ខសមុទយអរិយសច្ច ។ ទុក្ខកើត ព្រោះអញ អញក្នុងទីនេះ សំដៅយកកិលេសគឺ អវិជ្ជា តណ្ហា មានះ ទិដ្ឋិ ឯ ទុក្ខកើតព្រោះតណ្ហា តណ្ហាក៏ជាកិលេស ម្ល៉ោះហើយវាកិលេសជាមួយតែគ្នា ដូចតែគ្នា គ្រាន់តែប្រែ ភាសានិយាយឲ្យងាយស្តាប់តែប៉ុណ្ណោះ ។ ព្រោះហេតុដូចនោះ អ្នកស្តាប់ គប្បីជ្រាបថាទុក្ខកើតព្រោះអញ ឬ ទុក្ខកើត ព្រោះតណ្ហា ប្លែកគ្នាតែ ព្យញ្ជនៈ គឺតួអក្សរ ឯអត្ថៈ គឺសេចក្តីដូចគ្នាទាំងស្រុង ។

អញ របស់អញ អញទាំងអស់ តែគ្មានអញសោះ កន្លែងណា
ម្តេចមិននាំគ្នា ប្រើបញ្ញា ពិចារណារកការណ៍ពិតរឿងអញ ។

# អញ្ញ តាមផ្លូវលោក

អញ តាមផ្លូវធម៌ បានអធិប្បាយមកច្រើនគួរសមហើយ ។ ឥឡូវនេះ ដើម្បីឲ្យងាយយល់ និយាយអញតាមផ្លូវលោកម្តង ។ អញតាមផ្លូវលោក មិនមែនផុតពីធម៌ទេ នៅតែធម៌ដដែល ប៉ុន្តែ និយាយតាមដែលមនុស្សលោកគេយល់គេនិយាយគ្នា ។ មនុស្សលោកគេមិនចេះមិនដឹងរឿងខន្ធ ៥ គេមិនស្គាល់កិលេសទេ តែគេដឹងថា គេកើតមកមានរូបកាយមានខ្លួន គេក៏សំគាល់ថា រូបអញ ខ្លួនអញ អ្វីៗ ដែលផ្សំគ្នាបានទៅជារូបជាខ្លួន (សក់ រោម ក្រចកជាដើម) អញដែរ នៅក្នុងខ្លួនមានអ្វីចេះនឹកគិតគឺចិត្ត ចិត្តហ្នឹងអញដែរ ។ ដូចនេះ រូបនិងចិត្តគឺអញ បើមានអញហើយ មានរបស់អញ មានញាតិអញ មានពួកបក្សគណៈអញ... ។ អញហ្នឹងសំខាន់ណាស់ ធំណាស់ នរណាប៉ះមិនបានទេ ប៉ុន្តែបើអញប៉ះពារទៅលើគេវិញបាន ហើយធ្វើឲ្យអញហ្នឹងបែបធំសម្បើមទៀតផង ។ កុំថាតែមនុស្សមានអញ សូម្បីសត្វតិរច្ឆាន កូនឆ្កែ កូនឆ្មា... ក៏មានអញដែរ ពេលណាយើងលូកដៃទៅរកចាប់វា វាគ្រហឹម ហ៊ឺៗ... អញ អញ ។ មនុស្សលោកគេប្រើអញច្រើនណាស់ គ្រប់ទីកន្លែងទាំងអស់ ទីណាមានបុគ្គលល្ងិតល្ងង់ច្រើន ទីនោះមានបុគ្គលអញរឹតតែច្រើន ទីណាមានបុគ្គលភ្លឺស្វាងច្រើន ទីនោះ មានបុគ្គលអញតិចចុះ តាមកម្រិតនៃការភ្លឺស្វាងនោះ ។ អញនាំឲ្យកើត ទុក្ខទោស ច្រើនណាស់ ដល់ខ្លួនឯងផង ដល់គេឯទៀតផង

បើប្រើអញច្រើន ទុក្ខទោសកើតច្រើន បើប្រើអញតិច ទុក្ខទោស កើតតិច ជាលំដាប់មក ។ ដើម្បីងាយយល់ សូមលើកជា ឧទាហរណ៍-

## គ្រួសារមួយ

គ្រួសារមួយ ប្រកបដោយសមាជិកគឺ ប្តី ប្រពន្ធ កូន ។ បើសមាជិកគ្រួសារនោះ មិនសូវមានអញ គេប្រើយើងជំនួសវិញ ធ្វើអ្វីៗយើងពិគ្រោះគ្នា យើងចេះស្តាប់គ្នា យើងគោរពគ្នា គ្រួសារនោះ មានសេចក្តីសុខចំរើន ត្រជាក់ត្រជុំ ក្សេមក្សាន្តគ្រាន់បើ ។ បើសមាជិកគ្រួសារនោះ គេប្រើអញរៀងៗ ខ្លួន ប្តីគេថា អញប្តី អញចង់ស៊ីផឹករាំច្រៀងស្រេចតែអញ ឯងកុំចេះ... ប្រពន្ធគេថា អញប្រពន្ធ បើមិនឲ្យអញនិយាយផង អញលេងបៀ ក៏ស្រេចតែអញដែរ កូនគេថា ខ្ញុំ(អញ) មិនទៅសាលារៀនទេ ដើរលេងសប្បាយជាង... ។ សូមលោក អ្នកគិតប៉ាន់ស្មានមើល តើមានផលវិបាកយ៉ាងម៉េច? ទុក្ខ ទោស និង បញ្ហាផ្សេងៗ នឹងកើតឡើងយ៉ាងម៉េច? មិនបាច់សង្ស័យទេ អញតែម្នាក់ ពិបាកមិនស្មើរទៅហើយ ទំរាំអញដល់ទៅ ៣ នាក់មិនបាច់ថ្លែងទេ ទឹកភ្នែកនឹងហូរមិនស្ងើយឡើយ។

## ឃុំ ស្រុក ខេត្ត

ក្នុងឃុំនីមួយៗ បើមន្ត្រីឃុំគេយកអញជាត្រីមុខហើយ ប្រជារាស្ត្រនឹងរងទុក្ខលំបាកក្តៅក្រហាយជាពុំខាន កុំនាំគ្នាទាមទាររកយុត្តិធម៌អីច្រើនពេក ព្រោះ អំណាចសព្វយ៉ាងនៅលើមេឃុំ គេចាប់មនុស្សយកទៅឃុំក៏បាន

បានជាគេ ហៅថាមេឃុំៗ ។ ពីដើម នៅសាលាឃុំ(កន្លែងមេឃុំធ្វើការ) មានច្រវាក់ មានខ្នោះឈើ សំរាប់ដាក់មនុស្សទោស គ្រាន់តែគ្មានលុយបង់កាត គេ ចាប់ដាក់ខ្នោះដែរ គ្រាន់តែផឹកស្រាឡូឡាសំដីបែបធំបន្តិចគេចាប់ដាក់ខ្នោះដែរ ដាក់ខ្នោះ ឬ ច្រវាក់ឲ្យដេកផ្ទាល់នឹងដី គេថា អ្ហែងដឹងទេ អញមេឃុំ...។ មកដល់សព្វថ្ងៃនេះហើយ នៅតែមិនទាន់អន់ជាងពីដើមប៉ុន្មានដែរ រដ្ឋអំណាចគេមិនរវល់ស្តាប់សម្លេងប្រជាជន (ពលរដ្ឋ) ប៉ុន្មានទេ មើលតែ គេធ្វើច្បាប់បោះឆ្នោតជ្រើសរើសមេឃុំដឹងហើយ។ បើមិនប្រញាប់ដឹងទេ ប្រយ័ត្នបាត់ខ្លួន ។ នេះ ជាផលដែលកើតមកពីអញពីពួកអញនិយម ។ ស្រុក ខេត្ត ក៏មានវិធានការដូចគ្នានេះដែរ ។

ចៅហ្វាយស្រុក ចៅហ្វាយខេត្ត : ចៅ ប្រែថា លោកម្ចាស់ ហ្វាយ ប្រែថា ផ្តៅ ចៅហ្វាយស្រុក គឺលោកម្ចាស់អ្នកកាន់រំពាត់ផ្តៅ (ក្រោយមកគេប្រើរំពាត់ក្តោជំនួសវិញ ព្រោះវាមានប្រសិទ្ធិភាពជាង) ត្រួតត្រាស្រុកនីមួយៗ ចៅហ្វាយខេត្ត គឺលោកម្ចាស់អ្នកកាន់រំពាត់ផ្តៅ ត្រួតត្រាខេត្តនីមួយៗ ។ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត មានតួនាទី និង អំណាចដូចជាមេឃុំដែរ គ្រាន់តែច្រើនជាង ធំជាង ជាលំដាប់ឡើងទៅ ។ ពីបុរាណកាល ចៅហ្វាយស្រុក ចៅហ្វាយខេត្តខ្លះ មានតំណែងជាស្តេចត្រាញ់អាចសម្លាប់មនុស្សបាន ។ លោកចៅហ្វាយ នរណាធ្វើឲ្យឃ្នើសចិត្តបន្តិចមិនបានទេ លោកដាក់នឹងរំពាត់ផ្តៅរមូលខ្លួនឥឡូវហ្នឹង អ្ហែងដឹងទេអញចៅហ្វាយស្រុក អញចៅហ្វាយខេត្ត ។

ឥឡូវនេះ គេប្រែឈ្មោះ ចៅហ្វាយស្រុក ជាអភិបាលស្រុក ប្រែថា អ្នកថែរក្សាស្រុក , ចៅហ្វាយខេត្ត ជាអភិបាលខេត្ត ប្រែថា អ្នកថែរក្សាខេត្ត បែបដូចធូរបន្តិច ប៉ុន្តែគ្រាន់តែធូរឈ្មោះទេ ខ្មោចចៅហ្វាយស្រុក ចៅហ្វាយខេត្ត នៅតែមកលងដដែល រាស្ត្រនៅទុក្ខលំបាកច្រើនទៀតណាស់ សូមលោកបន្ថយអញបន្តិចទៅ ។

**រាជធានី**

រាជធានីភ្នំពេញ ជាទីក្រុងធំចម្បងនៃប្រទេសកម្ពុជា ជាទីប្រជុំនៃក្សត្រ មន្ត្រី គហបតី អ្នកមាន អ្នកក្រគ្រប់ប្រភេទ ។ សូម្បីអ្នកខ្លាំងៗ អញ ។ ក៏មានច្រើននៅទីនេះដែរ អញ ព្រះអង្គម្ចាស់ អញនាយករដ្ឋមន្ត្រី អញនាយករដ្ឋមន្ត្រីទី១ អញនាយករដ្ឋមន្ត្រីទី២ ប៉ុន្តែ អញអ្នករំដោះ អញរដ្ឋមន្ត្រី អញឯកឧត្តម អញលោកជំទាវ អញឧត្តមសេនីយ៍ អញគហបតី អញឧកញ៉ា អញសញ្ញាបត្រធំ... ។ល។ អញពាសពេញទីក្រុង មិនដឹងណាស្លាប់ណា ដណ្តើមអំណាច ដណ្តើមទ្រព្យ ងាប់រាស្ត្រ ងាប់ជាតិ ដូចពាក្យចាស់ថា ក្របីជល់គ្នា ងាប់ឯស្រមោចសង្ខារ ។

ធម្មនីតិ រាជនីតិ ថា-

**អនាយកា វិនស្សន្តិ នស្សន្តិ ពហុនាយកា**
**ថិនាយកា វិនស្សន្តិ នស្សន្តិ សុសុនាយកា**

ជនមិនមាននាយកក៏វិនាស នាយកច្រើនពាសវិនាសដូចគ្នា
ស្រីអាក្រក់ជានាយកក៏ខូចអាសា កំឡោះយង់ឃ្នងជានាយកក៏វិនាស ។

## អ្នកក្រៅក្រុង អ្នកក្រៅច្បាប់

អ្នកធ្វើការនៅព្រៃគេថា បើនៅទីក្រុងស្រេចតែឯង នៅក្នុងព្រៃស្រេចតែអញ អញចង់កាប់ឈើចង់បាញ់សត្វ... ស្រេចតែអញ ដោយបានអ្នកក្រុងខ្លះចូលដៃផ្សំផង មានអីវាលល្វឹង... ទឹកជនអើយ រាំងភ្លៀងអើយ ជាតិ និង រាស្ត្រទទួលរងទុក្ខទៅ ។ អ្នកក្រៅច្បាប់គេថា បើទុកអញនៅក្រៅច្បាប់ រឿងជីកត្បូង ស្រេចតែអញ មានអី ម៉ត់អស់ទៅ។ នេះផលវិបាក របស់អញ ។ យើងសព្វថ្ងៃ វាដើរមកដល់ហ្នឹង ដល់អញហ្នឹង ក្នុងប្រទេសក៏អញ ក្រៅប្រទេសក៏អញ អញគ្រប់គ្នា ។

## អ្នកបរទេស

ខ្មែរអ្នកនៅបរទេសឯណោះ ក៏អញសម្បើមគួរសមដែរ មិនចេះស្តាប់គ្នា មិនព្រមចូលគ្នា គេធ្វើវាទាស់អីចេះ វាខុសអីចុះ ទាល់តែអញធ្វើបានវាត្រូវ ដូចនេះ ៣,៤ នាក់បង្កើត សមាគមមួយ បែកគ្នាខ្ទេច រកកម្លាំងកសាងជាតិមិនបាន ។ ខ្ញុំបានប្រាប់គេមកយូរហើយថា ផ្ទះយើងភ្លើងទើបនឹងឆេះបន្តិចទេ ទ្រព្យសម្បត្តិនៅសល់ច្រើនណាស់ដែរ យើងត្រូវរួមគ្នាលត់ភ្លើងសិន យើងចង់ដេញយួន ត្រូវរួបរួមគ្នាដេញយួន មិនមែនបែកគ្នាដេញយួនទេ គ្រាន់តែឃើញយើងបែកគ្នាដេញវា យួនវាសើចទៅហើយ... មានតែញុះឲ្យយើងបែកគ្នាថែមទៀត... ។ ពួកអ្នកខ្លាំងៗ គេឆ្លើយថា លោកតាឯង មិនដឹងអីទេ រឿងស្រុកទេសនោះ មានតែពួកគេ(អញ)បានដឹង គេក៏ចាប់តាំងបង្កើតបក្សសន្និកសន្ទាប់ចូលប្រឡូកបោះឆ្នោត អ្នកខ្លះពូកែ

អែបអបបានបុណ្យសក្តិ ផុះពោះធាត់ធំឡើងឯកឧត្តមសន្សំទ្រព្យទុកទៅក៏មាន អ្នកខ្លះចាញ់បោកគេ ក្រៀមក្រំចិត្តអស់ទ្រព្យងាប់ខ្លួនទៅក៏មាន អ្នកខ្លះសល់តែខោត្រឡប់មកវិញក៏មាន ។ នេះ ជាផលដែលគេយល់ថា មានតែអញទេ ចេះច្រើនដឹងច្រើន ។

## វត្តនៅបរទេស

ខ្មែរយើងទោះបីទៅរស់នៅឯបរទេសក៏ដោយ ក៏នៅតែស្រឡាញ់ និងថែរក្សាវប្បធម៌ជាតិរបស់ខ្លួន បាននាំគ្នាបង្កើតវត្តអារាមជាច្រើនគួរឲ្យសរសើរ ប៉ុន្តែ វាមានទាស់ត្រង់ដែលមាន បុគ្គលខ្លះនាំយកអញទៅផង អញប្រធាន អញអគ្គលេខាធិការ អញអាចារ្យ ។ល។ ឯព្រះសង្ឃយើងថាបួសលះបាបសន្សំបុណ្យ ប៉ុន្តែ ស្ពាយអញយកទៅជាមួយផងដែរ អញចៅអធិការ អញគ្រូសូត្រ ។ល។ ម៉្លោះហើយ ព្រះសង្ឃទាស់នឹងព្រះសង្ឃ ក៏មានវត្តខ្លះចូលវស្សា ២ដង គ្រូសូត្រគេថា ឆ្នាំនេះអត់មានអធិកមាសទេ គេនាំគ្នាចូលវស្សាមុនមួយចំនួនទៅ ចៅអធិការគេថា ឆ្នាំនេះមានតម្រួតខែ អញមិនទាន់ចូលទេ ចាំចូលវស្សាខែក្រោយ-----------គ្រាន់តែប៉ុណ្ណឹង រកវិធីសាមគ្គីគ្នាមិនកើត ។ វត្តខ្លះ គណៈកម្មការ និង ព្រះសង្ឃដណ្តើមគ្នាធំ ឈ្លោះទាស់ទែង ប្តឹងផ្តល់គ្នាក៏មាន មានវត្តខ្លះដំណើរទៅបានល្អ គួរឲ្យអនុមោទនាក៏មានខ្លះដែរ ។ ឯវត្តនៅស្រុកខ្មែរ ប្រហែលជាមានអញមិនស្មើរដែរមើលទៅ ។ ហេតុនេះ យើងត្រូវនាំគ្នាលះអញបន្ថយអញ ជាប្រញាប់ ទើបសាសនាយើង ជាតិយើង មានសង្ឃឹមនឹង

ថ្មីថ្មើងឡើងវិញបាន ។

# រឿងផ្សេងៗ

## សង្គមចាស់

ឆ្នាំមួយមានទឹកជន់លិចក្រុងភ្នំពេញ ខ្ញុំចេញពីសាលាបាលីជាន់ខ្ពស់ បានឃើញភ្នាក់ងារបូមទឹក កំពុងរៀបចំបូមទឹកពីក្នុងស្រះមុខវត្តបទុមវតី ចេញទៅទន្លេ នគរបាលបានដាក់របាំង និង យាមការពារ កុំឲ្យយានជំនិះឆ្លងកាត់តាមផ្លូវនោះ ស្រាប់តែមានត្រីចក្រយានមួយ ចូលមកតាមផ្លូវនោះ នគរបាលឃាត់ អ្នកជំជិះត្រីចក្រយាននោះ ស្រែកឡើងថា អ្ហែងមិនដឹងទេ អញរដ្ឋមន្ត្រី... ។ នគរបាល បះសក់ ។

## សង្គម ហេង សំរិន ហ៊ុនសែន

ខ្ញុំទៅដេកពេទ្យកាល់ម៉ែត ពេលទំនេរ គ្រូពេទ្យបានមកគួរសម សួរសុខទុក្ខខ្ញុំ... គាត់តំណាលថា ពីថ្ងៃមុន មានបងប្អូនអ្នកធំមកដេកពេទ្យនេះ ដើម្បីត្រូវវះកាត់ ។ ពេទ្យយកក្រដាសជូនលោកធំនោះចុះហត្ថលេខា យល់ព្រមឲ្យវះកាត់ លោកធំគំហកថា ចាំបាច់ចុះហត្ថលេខាអីទៀត បើអញនៅអណ្ដឹងហើយ ពេទ្យយកក្រដាសនោះហែកចោលទៅ ប៉ុន្តែ មិនមានគ្រូពេទ្យណាហ៊ានវះកាត់សោះ ។ លោកធំខឹងទៅប្ដឹងចៅហ្វាយពេទ្យ វៀតណាមដែលគ្រួតមន្ទីរពេទ្យកាល់ម៉ែត ចៅហ្វាយអញ្ជើញមកសួរគ្រូពេទ្យ គ្រូពេទ្យម៉េចក៏មិនវះកាត់អ្នកជម្ងឺនេះទៅ គ្រូពេទ្យឆ្លើយថា លោកធំមិនព្រមចុះហត្ថលេខា បានជាមិនហ៊ានវះកាត់។ អ្ហោះ! ម៉េចក៏មិនចុះហត្ថលេខាឲ្យ

គេ លោកធំអិញអុញទាល់ស្មៀត ងាកសួររកក្រដាស ពេទ្យឆ្លើយថា ហែកចោលអស់ទៅហើយ ទំរាំទៅរកក្រដាសថ្មីមកទៀត ខាតពេលអស់សន្ធឹក បើជម្ងឺធ្ងន់ខ្លាំង ប្រហែលជាមិនធន់ទេ ។ នេះ រឿងអញ ។

ខ្ញុំទៅពេទ្យព្រះសង្ឃ ដើម្បីគ្រូពេទ្យត្រួតពិនិត្យរោគ បានជួបនឹងលោកធំម្នាក់ កំពុងស្រែកឡូឡា ស្អែងដឹងទេ អញរំដោះក្បាលស្អែងរាល់គ្នា... ។ មនុស្សទាំងអស់ស្ងាត់ច្រៀប ខ្ញុំក៏ស្ងាត់នឹងគេដែរ ក្រោយពីពេលដែលលោកធំចេញទៅ ខ្ញុំសួរពេទ្យ នរណាគេ ឡូឡាអំបាញ់មិញនេះ ពេទ្យឆ្លើយថា លោក... សាន ។ ខ្ញុំសួរបន្ត ចុះមានរឿងយ៉ាងម៉េច? ពេទ្យឆ្លើយថា បងប្អូនលោកធំឈឺ ចូលមកព្យាបាល ពេទ្យត្រូវសួរកត់ឈ្មោះតាមរបៀប ប៉ុន្តែ លោកធំក្រោធខឹង ម៉េចចាំបាច់សួរអី មិនយកអ្នកជម្ងឺទៅព្យាបាលទៅ... ។ នេះ រឿងលោកធំ រឿងអញ ។

ខ្ញុំនៅវត្ត គ្រូពេទ្យធ្វើការនៅមន្ទីរពេទ្យចិន អញ្ជើញទៅធ្វើបុណ្យ... គាត់តំណាលថា ពីថ្ងៃមុន អ្នកបម្រើលោកធំទៅដេកពេទ្យ ពួកពេទ្យរត់ប្រសេចប្រសាច ដើម្បីព្យាបាលអ្នកជម្ងឺនោះ ។ ខ្ញុំសួរថា ម៉េចក៏អញ្ចឹង! គ្រូពេទ្យឆ្លើយថា ខ្លាចអ្នកជម្ងឺនោះទៅរាយការណ៍ប្រាប់លោកធំ... លោកគ្រូអើយ សព្វថ្ងៃនេះ ខ្លាចតាំងពីអ្នកបប្រើគេ... រាស្ត្រធ្វើស្តេច បែបពិបាកជាងស្តេចធ្វើស្តេចទៅទៀត ។ ខ្ញុំថា អើ! អាចពិតខ្លះ មិនពិតខ្លះ ក៏បាន ព្រោះស្តេចក៏មិនអន់ប៉ុន្មានដែរ ។ លោកគ្រូពេទ្យអើយ លោកធ្វើនាម៉ឺនផង ខ្លាចគេដល់ម្លឹងទៅហើយ ចុះរាស្ត្រយ៉ាងណាទៅ នៅកណ្តាល

ក្រុងយ៉ាងណឹងទៅហើយ ចុះតាមជនបទ មាត់ញក យ៉ាងណាទៅ! ។ ពុទ្ធោ អើយ ពុទ្ធោ! រាស្ត្រក្រីក្រ បាននរណាជួយ ។

ខ្ញុំនៅវត្ត គេមកតំណាលប្រាប់ថា ពីថ្ងៃមុន នៅបន្ទប់វះកាត់ ខេត្តកំពង់ចាម គ្រូពេទ្យវៀតណាមជក់បារី ពេទ្យអន្តរជាតិថា ម៉េចក៏លោកជក់បារីក្នុងបន្ទប់វះកាត់ ពេទ្យវៀតណាមឆ្លើយ ដីនេះអញរំដោះបាន អញចង់ធ្វើអីស្រេចតែអញ ពេទ្យអន្តរជាតិនិយាយថា ច្បាប់ពេទ្យក្នុងបន្ទប់វះកាត់ហាមជក់បារី... ពេទ្យវៀតណាមខឹងទៅប្ដឹងចៅហ្វាយខេត្ត ចៅហ្វាយខេត្តអញ្ជើញមក ដេញពេទ្យអន្តរជាតិឲ្យចេញពីខេត្តកំពង់ចាម ពេទ្យអន្តរជាតិនិយាយថា ពេទ្យដែលនិយាយរឿងជក់បារីតែម្នាក់ទេ ចុះពួកខ្ញុំយ៉ាងម៉េចដែរ? ចៅហ្វាយខេត្ត លើកដៃបណ្ដេញចេញ ព្រមទាំងមានវាចាថា ពួកឯងទាំងអស់គ្នា ត្រូវតែចេញពីខេត្តកំពង់ចាម... ។ ពេទ្យអន្តរជាតិទំលបញ្ហារៀបចំអីវ៉ាន់ធ្វើដំណើរចេញ លុះមកដល់ភ្នំពេញ អ្នកធំខ្មែរនៅភ្នំពេញភ័យ រត់ទៅសុំអង្វរករពេទ្យអន្តរជាតិ កុំឲ្យធ្វើដំណើរមាតុភូមិនិវត្តន៍ សូមលោកជួយខ្មែរតទៅទៀត... ។ រឿងអញ នៅមានច្រើនណាស់ តែសង្ខេបត្រឹមប៉ុណ្ណឹងសិនចុះ ។

ព្រះពុទ្ធ សម្ដែងថា-

> ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុក្ខា
> ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ
> តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា

ការបួសក៏លំបាក ការត្រេកអរនឹងផ្នួសក៏លំបាក ផ្ទះគ្រប់គ្រងមិនល្អក៏លំបាក ការនៅរួមជាមួយមនុស្សស្មើៗគ្នា (គឺអញគ្រប់តែគ្នា) ក៏លំបាក ការធ្វើដំណើរឆ្ងាយ គឺអន្ទោលទៅក្នុងវដ្តសំសារក៏លំបាក ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយ និង មិនគប្បីជាអ្នកមានទុក្ខជាប់តាមរហូតឡើយ ។

អញអើយ អើយអញ អញច្រើនណាស់
អញពេញ អញពាស គ្រប់តែគ្នា
អញច្រើន ទុក្ខច្រើន រាល់វេលា
នាំគ្នាលះអញ ចេញចោលទៅ ៕

# មិនមានអញ ក្នុងខន្ធប្រាំ

យើងសំគាល់រូបថារូបអញ　　វេទនា សញ្ញា អញដែរ
សង្ខារ វិញ្ញាណ អញហូរហែ　　អ្វីៗអញដែរ អញទាំងអស់ ។
បើវែកញែកមើលនៅក្នុងរូប　　មិនឃើញមានអ្វីជាអញសោះ
ឃើញ ដី ទឹក ភ្លើង ខ្យល់ប៉ុណ្ណោះ　　មិនឃើញអញសោះនៅត្រង់ណា។
វេទនា ដឹងសោយសុខទុក្ខ　　គ្រប់មុខរាល់រូបរាល់អាត្មា
ផ្សំគ្នាកើតឡើងតាមហេតុការណ៍　　គ្មានអញអត្តាគួរអាឡោះ ។
ចំណែក សញ្ញាកត់ចំណាំ　　ចាំរូបសម្លេង ទាប និង ខ្ពស់
ខ្មៅ ស វែង ខ្លីអ្វីទាំងអស់　　ក្នុងនោះក៏គ្មានអត្តាដែរ ។
សង្ខារតាក់តែងផ្សំផ្គុំគិត　　កើតជាគំនិតច្រើនឥតល្ហែ
បាបបុណ្យគុណទោសរាល់ថ្ងៃខែ　　ក្នុងនោះក៏ដែរគ្មានអញទៀត ។
វិញ្ញាណឃើញរូបឮសម្លេង　　ធំក្លិនផ្សេងៗភ្លក្សរសជាតិ
រឹងទន់ត្រជាក់ក្តៅប៉ះបៀត　　ក្នុងនោះក៏ទៀតគ្មានអញឡើយ ។
យើងជឿប្រកាន់ស្មានតាមគ្នា　　អស់ពេលវេលាមកយូរហើយ
កើតទុក្ខតានតឹងចិត្តឥតស្បើយ　　អ្នកកើយឈប់ជឿខុសទៀតទៅ ។

## អស់អញបានសុខ

កើត ចាស់ ឈឺ ស្លាប់របស់វា យើងនាំគ្នាថា របស់អញ
កើតទុក្ខក្រៀមមុខបាយមិនឆ្ងាញ់ ព្រោះមិនតាមអញបន្តិចសោះ ។
កើតចាស់ឈឺស្លាប់របស់វា កុំនាំគ្នាសោកស្តាយស្រណោះ
ព្រោះសុទ្ធតែរឿងវាទាំងអស់ គ្មានរឿងអញសោះបន្តិចណា ។
បើយើងយល់ថាគ្មានអញទេ ទ្រូងយើងបានល្ហែ ស្បើយទុក្ខា
គ្មានខ្លួនគ្មានអញគ្មានអត្តា ជាដុំសង្ខារទេអ្នកកើយ ។
ដកចិត្តឲ្យផុតពីខន្ធប្រាំ លែងប្រកាន់មាំអ្វីទៀតឡើយ
អស់អញនិងរបស់អញហើយ បានដល់ត្រាណត្រើយ បរមសុខ ។

## អញរំដោះក្បាលឯង

អញរំដោះក្បាលឯងរាល់គ្នា ម៉េចចង់ទាមទាររកអីទៀត
ពួកឯងរាល់គ្នាចោលមៀត អ្នកមានមារយាទគឺពួកអញ ។
អញថាយ៉ាងម៉េចធ្វើអីចឹង កុំអួតចេះដឹងនាំឲ្យគ្នាញ់
ប្រយ័ត្នអញឲ្យគេលបបាញ់ សម្លាប់ចោលចេញអស់ផុតពូជ ។
រឿងអីទាំងអស់ស្រេចតែអញ ពួកឯងអ្នកចាញ់កុំចេចចូច
និយាយពីរឿងអញខិលខូច ប្រយ័ត្នផុតពូជពីកម្ពុជា ។
ទ្រព្យធនទឹកដីព្រៃព្រឹក្សា អនេកប្រការអញចែកគ្នា
បក្សប្រជាជនកម្ពុជា និង អ្នកលួនវារគាំទ្រអញ ។

ពួកឯងគ្រាន់តែរស់បានហើយ | នៃរ៉ឺយ! កុំចង់ទាររកឆ្ងាញ់
សប្បាយហ៊ឺហាស្រេចពួកអញ | ត្រង់ណាខ្វាញ់ៗអញចែកគ្នា ។
អញចង់ធ្វើអីស្រេចតែអញ | ពួកអញរំដោះកម្ពុជា
ចំណែកឯពួកអ្លែងរាល់គ្នា | រស់ក្បាលដោយសារតែអញទេ ។
អញអើយអើយអញធំអ្វីម្ល៉េះ | ម៉្ដេចអ្នកមិនចេះគិតគ្នាន់គ្នេរ
ទឹកដីទ្រព្យធនដែលជាកេរ | ដូនតាយើងគេទាំងអស់គ្នា ។
អញធំតែឯងនាំជាតិងាប់ | ប្រសើរខ្ពស់គាប់សាមគ្គា
សាមគ្គីចែកសុខគ្រប់គ្នីគ្នា | ទើបកម្ពុជាថ្កើងឡើងបាន ៕

## រឿងពិតនៅត្រង់ណា?

អ្នកខ្លះគេថាគេរំដោះ | ឲ្យខ្មែររួចរស់ពីប៉ុលពត
ខ្មែរខ្លះគេថាពួកហ្នឹងឆោត | ធ្វើឈ្នាន់យួនលោតចូលស្រុកខ្មែរ ។
យួនធ្វើផែនការមកយូរហើយ | រង់ចាំតែដល់ថ្ងៃដល់ខែ
នាំទ័ពចូលមកយកដីខ្មែរ | ហូរហែក្នុងនាមអ្នករំដោះ ។
រឿងរ៉ាវដែលពិតវាយ៉ាងម៉េច | រាស្ត្រខ្លះមិនទាន់ដឹងច្បាស់សោះ
នរណាដឹងពិតយ៉ាងក្បាយក្បោះ | ប្រាប់រាស្ត្រឲ្យអស់សង្ស័យទៅ ។
កុំឲ្យគ្នាភាន់គ្នាច្រឡំ | ទុកអ្នកមានគុណជាសត្រូវ
បើយួនមានធម៌ដូចម៉ែឪ | ខ្មែរត្រូវគោរពត្រូវសងគុណ ។
បើយួនកាន់សីលដូចខ្លាចាស់ | ខ្មែរត្រូវយល់ច្បាស់កុំស៊ីយស៊ុន
កុំទុកវាជាអ្នកមានគុណ | ត្រូវទុកដូចមុន សត្រូវស្លូពួជ ៕

# លោក អ្នកសប្បុរសដែលជួយឧបត្ថម្ភការបោះពុម្ព

| | | |
|---|---|---|
| ១- ឧបាសិកា សាន សៀក | ១០០០ | ហ្វ្រង្គ |
| ២- ឧបាសិកា មាស សាវឌី | ២០០ | " |
| ៣- ឧបាសិកា អាំង រ៉ុង | ៣០០ | " |
| ៤- ឧបាសិកា អ៊ុំង ម៉ាឡេង | ១០០ | " |
| ៥- លោក ទា ឡឹក ឆាយ | ៣០០ | " |
| ៦- លោក និង លោកស្រី មូល គីណា | ២០០ | " |
| ៧- អ្នកស្រី គ្រួច សារិន | ២០០ | " |
| ៨- លោកស្រី ស៊ុន តាំងគុយអេង | ១៥០ | " |
| ៩- លោកស្រី អ៊ិន ឆាយស៊ុន | ១០០ | " |
| ១០- ឧបាសិកា ឆាយ ជូ | ២០០ | " |
| ១១- ឧបាសិកា យី អេង ឡាំ | ២០០ | " |
| ១២- ឧបាសិកា ស៊ីសុវត្ថិ ក្រិស្សនារី | ១០០ | " |
| ១៣- ឧបាសិកា លាង ស៊ីម | ២០០ | " |
| ១៤- ឧបាសិកា ធិន ហុង (ពៅ) | ១០០ | " |
| ១៥- ឧបាសិកា អៀ នី | ១០០ | " |
| ១៦- អ្នកស្រី យស សោធរា | ២០០ | " |
| ១៧- លោក លោកស្រី ឃួន ថ្ងៃ ចំណាន | ១០០ | " |

| | | | |
|---|---|---|---|
| ១៨- | លោក ហ៊ិត សម្បត្តិ អ្នកស្រី ហ៊ិត ស៊ីវហាវ | ១០០ | ដុល្លា |
| ១៩- | ឧបាសក ឧបាសិកា មិន ធូ | ១០០ | ហ្វ្រង្គ |
| ២០- | ឧបាសក លិម ប៉ាំ ឧបាសិកា ឈា ប៉ាំវតេ | ១០០ | " |
| ២១- | ឧបាសិកា ឈា ឆាត់ឌី | ១០០ | " |
| ២២- | ជូនជី សុក ចម ចារ្ងន | ១០០ | " |
| ២៣- | ឧបាសក អៀង | ១០០ | " |
| ២៤- | លោក អ៊ឹង ប៊ុនថេង អ្នកស្រី ស៊ីវ ហ៊ុយគាវ | ៥០០ | " |
| ២៥- | អ្នកស្រី ឆាយ ស្នួម | ១០០ | " |
| ២៦- | អ្នកស្រី អោម ស៊ីថា | ១០០ | " |
| ២៧- | ឧបាសិកា សោម សុខន | ១០០ | " |
| ២៨- | នាង សោម វិសាខា | ១០០ | " |
| ២៩- | លោក សោម សុផល | ១០០ | " |
| ៣០- | ឧបាសិកា សុត ចំរើន | ១០០ | " |
| ៣១- | ឧបាសិកា ហ៊ុល ឃុត | ១០០ | " |
| ៣២- | ឧបាសិកា សេក ហេង | ១០០ | " |
| ៣៣- | ឧបាសិកា ឡាយ រ៉ុ | ២០០ | " |
| ៣៤- | លោក និង លោកស្រី ហាក់ ព្រួ | ១០០ | " |
| ៣៥- | លោក និង លោកស្រី អ៊ិន សារ៉េន | ១០០ | " |
| ៣៦- | លោក ចៅ គាន អ្នកស្រី យក់ ហាន | ១០០ | " |

៣៧- លោក ឡាយ ហួសេង អ្នកស្រី អ៊ឹងហ្គេចសាង
៣៨- លោក អ៊ឹង តាក់ ឆាយ " ឡោ ប៊ួយឡាង
៣៩- លោក ឡាយ ខេង ជាង " ភួហៀងណាយ
៤០- លោក លឹម ហេង ម៉ុង " ឡាយ ស៊ួយីម
៤១- លោក ផុង សេងលី " ឡាយ ស៊ួហ៊ុន
៤២- លោក ឡាយ ខេង ឈុន ៣០០០ហ្វ្រង្គ
៤៣- លោកស្រី អ៊ឹង ហ្គេច តេង និង គ្រួសារ
៤៤- លោក អ៊ឹង ប៊ុនថេង អ្នកស្រី ស៊ីវ ហ៊ុយគាវ
៤៥- លោក អ៊ឹង ប៊ុនស៊ុង អ្នកស្រី ធីតា
៤៦- លោក អ៊ឹង ប៊ុនជាក់ អ្នកស្រី នាងមួយ
៤៧- នាង សុធា និង សាណេត
៤៨- ឧបាសក ឡៅ ហេង ឧបាសិកា តាន់សាយយុត ១០០ ហ្វ្រង្គ
៤៩- លោក ជួង ទឹម អ្នកស្រី ទិត ពៅ ១០០ "
៥០- " តាន់ កាង " ខាណុកយិប ១០០ "
៥១- " ផុង ហុងកៅ " ឡៅ ហុង ឡាយ ១០០ "
៥២- " ចន្ទ អាទ " ឡៅ ហុង ស៊ីម ១០០ "
៥៣- អ្នកស្រី ឡៅ សៃយីម ១០០ "
៥៤- អ្នកស្រី ជិប ហុងយេន ១០០ "
៥៥- ឧបាសិកា ញឹក សាយ៉ាន់ ១០០ "

| | | | | |
|---|---|---|---|---|
| ៥៦- | ឧបាសិកា | សៀប គីមហ៊ាង | ១០០ | ហ្វ្រង្គ |
| ៥៧- | " | អៀង ហុង | ១០០ | " |
| ៥៨- | " | ចាន់ ណាត | ១០០ | " |
| ៥៩- | " | អាត អេង | ១០០ | " |
| ៦០- | អ្នកស្រី | ប៉ាវ សារ៉េន | ១០០ | " |
| ៦១- | ឧបាសិកា | ឃិន ហុក ទីវ | ១០០ | " |
| ៦២- | " | ប៊ូ ដាណារ៉េត | ១០០ | " |
| ៦៣- | " | ឈា ឡេង ហាក់ | ១០០ | " |
| ៦៤- | " | ឈា ឆេង លន់ | ១០០ | " |
| ៦៥- | " | នៅ ទាវ ខេង ព្រមទាំងបុត្តធីតា | ២០០ | " |
| ៦៦- | " | សន ខាន់ ២០ដុល្លា+ | ២០០ | " |
| ៦៧- | " | ណែម លិមអ៊ាន | ១០០ | " |
| ៦៨- | " | ណែម លិមអ៊ិន | ១០០ | " |
| ៦៩- | " | បេង ហ៊ី | ១០០ | " |
| ៧០- | " | ប៉ៃ លិន | ១០០ | " |
| ៧១- | " | ហូ គីមឡេង | ១០០ | " |
| ៧២- | លោកស្រី | អ៊ូ បុប្ផា ព្រមទាំងស្វាមី | ១០០ | " |
| ៧៣- | នាង | នង ស៊ីនេត | ១០០ | " |
| ៧៤- | លោកស្រី | អ៊ូ យុវតី ព្រមទាំងស្វាមី | ១០០ | " |

| | | |
|---|---|---|
| ៧៥- | លោក អ៊ូ ទិត្យា ព្រមទាំងភរិយា | ១០០ហ្វ្រង្គ |
| ៧៦- | លោកស្រី អ៊ូ គង់ធីតា ព្រមទាំងស្វាមី | ១០០ " |
| ៧៧- | នាង កញ្ញា សាគូ បុប្ផាវតី | ៥០ " |
| ៧៨- | នាង កញ្ញា សាគូ បុប្ផាទេវី | ៥០ " |
| ៧៩- | លោក និង លោកស្រី នេត្រ គន្ធ | ២០០ " |
| ៨០- | លោក ណៃ ហួរ | ២០០ " |
| ៨១- | លោក និង អ្នកស្រី ទេព សំផន | ១០០ " |
| ៨២- | សាមណេរ ជួន ប៊ុនថា | ២០០ " |
| ៨៣- | ភិក្ខុ ស៊ុត សុភា ឥន្ទបញ្ញោ | ១០០ " |
| ៨៤- | ភិក្ខុ ធិន ភេន ឥន្ទបញ្ញោ | ២០០ " |
| ៨៥- | ក្រុមពុទ្ធបរិស័ទ | ៥០០ " |
| ៨៦- | ឧបាសិកា ឃុន តាំង អ៊ីម | ១០០ " |

យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ប្រគេន ជូនចំពោះវិញ្ញាណក្ខន្ធ នៃលោក អ្នកដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតាជាដើមផង ព្រមទាំងញាតិមិត្រទាំងឡាយផង ។ សូមលោក អ្នកដ៏មានគុណជាដើមនោះ អនុមោទនាទទួលយកនូវ ឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្ដីជ្រះថ្លារៀងៗខ្លួន កុំបីអាក់ខានឡើយ៕

កុំកាន់សាសនាឲ្យជ្រុលជ្រួស
ហួសដល់ជាតិស្លាប់ក៏មិនគិត
ស្មានថាខ្លួនឯងជាបណ្ឌិត
តែពិតជាល្ងិត ពាលសោះទេ ។

ព្រះពុទ្ធឲ្យធ្វើប្រយោជន៍ពីរ
គឺប្រយោជន៍ខ្លួន ប្រយោជន៍គេ
ម្ដេចអ្នកមិនចេះគិតគ្នាន់គ្នេរ
រេគិតធ្វើតែប្រយោជន៍ខ្លួន ។

ជាតិមានទុក្ខធំមិនជួយកែ
បែរកាន់សាសនាបែបមាំមួន
ទុកឲ្យជាតិស្លាប់ដោយសៀមយួន
ខ្លួនហ្នឹងពិតជាពាលពេញទី ៕

បុគ្គលអ្នកមានអញច្រើន មានអញក្រាស់ តណ្ហា របស់គេ ក៏មានច្រើន មានក្រាស់ដែរ ។ គេចង់សប្បាយនឹង រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ មិនចេះឆ្អែត មិនចេះស្កប់ស្កល់ ។ ចង់សប្បាយ បើគិតមិនឆ្ងាយ ស្មានថាសេចក្តីសុខ បើគិតឲ្យល្អិត គ្រប់មុខ ក្នុងសប្បាយនោះ មានទុក្ខច្រើនណាស់ ។ ចង់សប្បាយ មុននឹងសប្បាយបន្តិចនោះ តើមានទុក្ខអ្វីខ្លះ? ពេលយើងសប្បាយ តើគេឯទៀតសប្បាយឬទេ? ប្តីប្រពន្ធ កូន ចៅ គេសប្បាយ ដែរឬទេ? សង្គម សុខសប្បាយដែរឬទេ? ក្រោយពីសប្បាយទៅ តើមានទុក្ខ មានបញ្ហាអីខ្លះដែរ? យើងត្រូវគិតឲ្យជ្រៅ គិតឲ្យវែងឆ្ងាយ គិតឲ្យម៉ត់ចត់ល្អ ។ តណ្ហា ដូចជាទឹកអំបិល ផឹកមិនចេះឆ្អែតទេ រឹតតែផឹក រឹតតែស្រេក ។


**វត្តពោធិវង្ស**

101, Bd de la République
77420 Champs sur Marne
Tél. 01.60.06.44.98
Fax. 01.64.62.17.41